ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# ផែនការសកម្មភាព
# សម្រាប់អនុវត្តឯកសារគោលនយោបាយ ស្តីពី ការជំរុញ ផលិតកម្មស្រូវ និង ការនាំចេញអង្ករ



*រៀបចំដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

ខែ មេសា ឆ្នាំ ២០១១

អាសយដ្ឋាន លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

# មាតិកា


| | |
|---|---|
| | ទំព័រ |
| **អារម្ភកថា** | ២ |
| **ផ្នែកទី ១: យុទ្ធសាស្ត្រក្នុងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ** | ៤ |
| I- សេចក្តីផ្តើម | ៤ |
| II- ចក្ខុវិស័យ និង យុទ្ធសាស្ត្រក្នុងការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ | ៥ |
| ក- បញ្ហាប្រឈម និង កាលានុវត្តភាព ក្នុងផលិតកម្ម កែច្នៃ និងនាំចេញអង្ករ | ៦ |
| ខ- ចក្ខុវិស័យ និង ទិសដៅយុទ្ធសាស្ត្រ | ៧ |
| គ- អភិក្រម និង គោលការណ៍ប្រតិបត្តិ | ៨ |
| **ផ្នែកទី ២: ផែនការសកម្មភាព សម្រាប់អនុវត្តឯកសារគោលនយោបាយ ស្តីពី ការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ** | ១០ |
| I- ផែនការសកម្មភាព | ១០ |
| ១.១ វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវ | ១០ |
| ១.២ វិធានការពាក់ពន្ធ័នឹងការប្រមូលទិញ និងការកែច្នៃស្រូវ | ២១ |
| ១.៣ វិធានការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករ | ២២ |
| ១.៤ វិធានការស្វែងរកទីផ្សារ | ២៤ |
| II- គម្រោងថវិកាសម្រាប់អនុវត្តសកម្មភាព | ២៦ |
| III- យន្តការអនុវត្ត ការតាមដាននិងវាយតម្លៃ | ២៦ |
| ១-យន្តការអនុវត្ត | ២៦ |
| ២-ការតាមដាននិងវាយតម្លៃ | ២៧ |
| IV- ការគ្រប់គ្រងហានិភ័យ | ២៧ |
| V- សេចក្តីសន្និដ្ឋាន | ២៨ |

# អារម្ភកថា

ឯកសារគោលនយោបាយ ស្តីពី «**ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**» ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការយ៉ាងឱឡារិក កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ កន្លងទៅនេះ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ហើយដែលគ្រប់ភាគីពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវតែរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវទិសដៅ និងគោលបំណងដ៏ស៊ីជម្រៅ ដូចដែលបានកំណត់ក្នុងឯកសារគោលនយោបាយនេះ។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលំអិតរបស់ខ្លួន សំដៅឆ្លើយតប និង សម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយ ស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ បានកំណត់ច្បាស់ នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺ: (ទី១) វិធានការគោលនយោបាយ ដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ការប្រមូលទិញ និងការកែច្នៃ (ទី៣) ប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយ ដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។

ដើម្បីឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ "**ការបង្កើនផលិតភាព** ពិសេស ប្រពលវប្បកម្មដំណាំស្រូវ និង **ពិពិធភាវូបនីយកម្មកសិកម្ម**" គឺជាចំណុចគន្លឹះដែលត្រូវយកចិត្តទុកដាក់ និងផ្តោតមុខព្រួញជាសំខាន់ ទៅលើការបង្កើនសេវាកម្ម និងកិច្ចអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ ពិសេសគឺការកំណត់ប្រភេទពូជស្រូវសំខាន់ៗ ស្របតាមតម្រូវការទីផ្សារ ។ល។ ម្យ៉ាងទៀត ការសម្របសម្រួល និងគាំទ្រវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ ស្របតាមតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ គឺជាយន្តការគន្លឹះចាំបាច់ និងត្រូវតែចូលរួមគាំទ្រឱ្យបានខ្លាំងក្លា។ ដោយឡែក ការប្រមូលផ្តុំផលិតកម្ម ក៏ជាចំណុចគ្រឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំ តាមរយៈ "សហគមន៍កសិកម្ម ឬ សហករណ៍កសិកម្ម" ពីព្រោះប្រសិនបើផលិតផលស្រូវនៅរាយប៉ាយគ្រប់ទីកន្លែង និងចម្រុះទៅដោយប្រភេទពូជច្រើនមុខនោះ គុណភាពស្រូវពិតជាមិនអាចឆ្លើយតបបានទៅនឹងសេចក្តីត្រូវការឡើយ។ ដូចនេះ ទាមទារឱ្យមានការប្រមូលផ្តុំផលិតកម្មជាចាំបាច់ ហើយសហគមន៍កសិកម្ម គឺជាមជ្ឈមណ្ឌលផលិត និង ផ្គត់ផ្គង់ដ៏សំខាន់នាពេលអនាគត។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងតម្រង់ទិសដៅនៃការធ្វើអន្តរាគមន៍ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីបង្កើនផលិតផលក្នុងទ្រង់ទ្រាយធំ នាពេលខាងមុខ ក៏ដូចជាការយកចិត្តទុកដាក់ខ្ពស់ដល់ផ្នែកឯកជន ពិសេស បណ្តាក្រុមហ៊ុនដែលចូលរួមក្នុងការធ្វើផលិតកម្មកសិកម្មនៅកម្ពុជាផងដែរ។

ការផ្សារភ្ជាប់រវាង ក្រុមអ្នកផលិត និង អ្នកប្រមូលទិញ តាមយន្តការ «ផលិតកម្មកសិកម្មតាមកិច្ចសន្យា»គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ ក្នុងការសម្រេចបាននូវទិសដៅគោលនយោបាយនេះ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានអំពីទីផ្សារស្រូវ ក៏ជាមធ្យោបាយដ៏ស័ក្តិសិទ្ធិមួយ ដើម្បីឲ្យកសិករ-ពាណិជ្ជករ មានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មកសិកម្មនេះ។ លើសពីនេះទៀតនោះ ការ

សម្រួលពាណិជ្ជកម្ម និង ការនាំចេញ តាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទ លិខិតបទដ្ឋាន ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាវិធានការចាំបាច់និងត្រូវពង្រឹងបន្ថែមទៀត។

ផ្អែកលើសារសំខាន់ និងភាពចាំបាច់ នៃឯកសារគោលនយោបាយ «ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំ នូវផែនការសកម្មភាពរបស់ខ្លួន ដោយបានលំអិតនូវអ្វីដែលជាសកម្មភាពអាទិភាព ក៏ដូចជាភារកិច្ចត្រូវអនុវត្ត និងបានដាក់ចុះជាសកម្មភាពជាក់ស្តែងនានា ដល់អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តវិធានការគោលនយោបាយនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ និងស្មារតីសន្សំសំចៃ។

យ៉ាងណាមិញ ការតាំងចិត្តយ៉ាងមុតមាំក្នុងការអនុវត្ត និងជំនះនូវរាល់ឧបសគ្គ ពីគ្រប់ស្រទាប់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការក្នុងអង្គភាពជំនាញនានា មន្ទីរកសិកម្មរាជធានី ខេត្ត ការរួមសហការពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងការបង្កើននូវថវិកាចំណាយរបស់រដ្ឋ ក៏ដូចជាការចូលរួមចំណែក ទាំងបច្ចេកទេសនិងធនធានថវិកា ពីបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់របស់កម្ពុជា ជាពិសេសការចូលរួមដោយពេញចិត្តពេញថ្លើមពីសំណាក់ប្រជាកសិករ ពិតជានឹងប្រែក្លាយផែនការសកម្មភាពនេះ ឲ្យទៅជាការអនុវត្តជាក់ស្តែង ដើម្បីទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់ ហើយឈានទៅសម្រេចបាន នូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនឿទុកចិត្តថា «ផែនការសកម្មភាព សម្រាប់អនុវត្តឯកសារគោលនយោបាយ ស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» ដែលបានប្រកាសដាក់ឲ្យអនុវត្តនាពេលនេះ ពិតជានឹងអាចអនុវត្តទៅបានប្រកបដោយជោគជ័យ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

# ផ្នែកទី ១

# យុទ្ធសាស្ត្រក្នុងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

## I- សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម និងមានប្រជាពលរដ្ឋភាគច្រើនលើសលុបរស់នៅទីជនបទ និង ប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ កម្លាំងពលកម្មរបស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានប្រមាណ ៧៤,២% នៃកម្លាំងពលកម្មសរុប វិស័យឧស្សាហកម្មមានត្រឹមតែ ៧% និង សេវាកម្មមានចំនួន ១៨,៨% (ទិន្នន័យស្ថិតិកម្ពុជា២០០៨)។ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណជា ២៩% ក្នុងឆ្នាំ២០១០ និង មានកំណើនវីកលូតលាស់ប្រចាំឆ្នាំក្នុងរង្វង់ពី ៤,៥-៥,៥% ។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងចាត់ទុកថាវិស័យកសិកម្ម គឺជាវិស័យដែលមានអាទិភាពខ្ពស់ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ និង កាត់បន្ថយភាពក្រីក្រ តាមរយៈ ការបង្កើនផលិតភាពកសិកម្ម ធានានូវស្ថេរភាពសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលគ្រួសារកសិករ ហើយដែលធានាបាននូវអតិរេកនៃផលិតផលកសិកម្មបំរើឱ្យការនាំចេញ។ ការលើកស្ទួយវិស័យកសិកម្ម គឺជាចំណុចគន្លឹះមួយដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកំពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការកែទម្រង់វិស័យជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូល ដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញ ជាពិសេស ការបង្កបង្កើនផលដំណាំជាយុទ្ធសាស្ត្រជាអាទិ៍ ដំណាំស្រូវ កៅស៊ូ ក៏ដូចជាដំណាំកសិ-ឧស្សាហកម្មជាយុទ្ធសាស្ត្រដ៏ទៃទៀត រួមទាំងការចិញ្ចឹមសត្វ និងនេសាទ ដើម្បីបំពេញបានទៅនឹងតម្រូវការប្រើប្រាស់ក្នុងស្រុក និងសំរាប់នាំចេញទៅទីផ្សារអន្តរជាតិ។ នៅពេលដែលពិភពលោកកំពុងជួបប្រទះវិបត្តិស្បៀង និងការធ្លាក់រួញចុះនៃសេដ្ឋកិច្ច កម្ពុជាបានខិតខំបង្កើននូវផលិតកម្មដំណាំស្បៀង សំដៅរួមចំណែកដោះស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពលអំណោយផលយ៉ាងធំធេង របស់វិស័យកសិកម្មនេះ ជាពិសេសសក្តានុពលដំណាំស្រូវ ដែលអាចពង្រីកបានទាំងផ្នែកផលិតកម្ម និងការនាំចេញ ហើយនឹងអាចចូលរួមលើកស្ទួយជីវភាពរស់នៅ របស់ប្រជាពលរដ្ឋតាមតំបន់ជនបទ និងបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នៃប្រទេសអ្នកផ្តល់ជំនួយ និងសំដៅជំរុញលើកកំពស់ បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ដោះស្រាយបានបញ្ហាសន្តិសុខស្បៀង និងបញ្ហាទីផ្សារនាំចេញកសិផល ក្នុងនិងក្រៅប្រទេស។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាន និងកំពុងស្រូបទាញបាននូវទុន

វិនិយោគ ទាំងពីអ្នកវិនិយោគក្នុងនិងក្រៅប្រទេស កាន់តែធំឡើងជាលំដាប់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ដោយឡែក សម្រាប់ការអភិវឌ្ឍវិស័យស្រូវអង្ករ «មាស ស» រាជរដ្ឋាភិបាលកម្ពុជា មានមហិច្ឆតាចង់ឲ្យប្រទេសកម្ពុជា ក្លាយទៅជាប្រទេសនាំចេញអង្ករធំមួយក្នុងតំបន់ សម្រាប់ផ្គត់ផ្គង់លើទីផ្សារពិភពលោក។ ក្នុងនយ័នេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ ២០១៥ ជាឆ្នាំគោលដៅ ដើម្បីសម្រេចធ្វើយ៉ាងណា ឲ្យអតិរេកស្រូវមានជាង ៤ លានតោន ហើយដែលអាចកែច្នៃជាអង្ករនាំចេញជាផ្លូវការ យ៉ាងតិចជាង ១ លាន តោន។

ដើម្បីសម្រេចបាននូវមហិច្ឆតាដ៏ធំធេងនេះ ឯកសារគោលនយោបាយស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» ត្រូវបានរៀបចំ និង ប្រកាសដាក់ឲ្យអនុវត្ត កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ កន្លងទៅ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាព ក្នុងការអនុវត្ត ឲ្យទទួលបានជោគជ័យនាពេលខាងមុខ។ ផ្អែកលើឯកសារគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំកសាងផែនការសកម្មភាពលំអិត ឆ្លើយតបទៅនឹងវិធានការគោលនយោបាយនីមួយៗ ដូចដែលបានចែងក្នុងឯកសារគោលនយោបាយនេះ ហើយមានការពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន ដែលត្រូវអនុវត្តក្នុងរយៈពេលខ្លី មធ្យម និង វែង នាពេលខាងមុខ។

## II- ចក្ខុវិស័យ និងយុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សំរាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតសំខាន់ទៅលើការ «**លើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម**» និង «**ពាណិជ្ជូបនីយកម្មកសិកម្ម**» ដោយធានាបាននូវការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំដៅលើកកម្ពស់វិស័យកសិកម្ម ឲ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការប្រើប្រាស់ធនធាន សំរាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេស ធាតុចូលកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ផ្លូវថ្នល់ ប្រពន្ធ័ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទាន ទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀង សំរាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

តែទោះជាយ៉ាងណាក្តី ផលិតកម្ម និងការនាំចេញផលិតផលកសិកម្ម ពិសេសផលិតផលស្រូវអង្ករ នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយ តាមរយៈ ការអនុវត្តនូវបណ្តាវិធានការបន្ទាន់ មធ្យម និងវែង ដើម្បីឲ្យសម្រេចបាននូវចក្ខុវិស័យ និងយុទ្ធសាស្ត្រ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ។

## ក.	បញ្ហាប្រឈម និង កាលានុវត្តភាព ក្នុងផលិតកម្ម កែច្នៃ និងនាំចេញអង្ករ

ក្នុងឯកសារគោលនយោបាយស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» បានបង្ហាញពីបញ្ហាប្រឈមក្នុងផលិតកម្ម ដំណើរការកែច្នៃ ការនាំចេញ និង ក៏បានបញ្ជាក់ពីកាលានុវត្តភាពរបស់កម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោម៖

### ក-១	បញ្ហាប្រឈម

### ១.	បញ្ហាប្រឈមក្នុងផលិតកម្ម

ផលស្រូវលើសសំរាប់ការនាំចេញ គឺនៅមានកំរិតទាប ពីព្រោះបើកម្ពុជាមានបំណងចង់នាំអង្ករចេញពី ៣ ទៅ ៤ លានតោនក្នុងមួយឆ្នាំៗ យើងត្រូវផលិតស្រូវយ៉ាងហោចណាស់ឲ្យបាន ១០-១១ លានតោន ដែលទាមទារឲ្យយើងដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលនាំឲ្យមានផលិតភាពទាប ដូចជាបញ្ហាគ្រប់គ្រង ការប្រើប្រាស់ដីផ្លី បញ្ហាទឹកស្រោចស្រព បញ្ហាសិក្សាស្រាវជ្រាវផ្សព្វផ្សាយបច្ចេកទេស បញ្ហាប្រពលវប្បកម្មដំណាំស្រូវ និងការរៀបចំរចនាសម្ព័ន្ធអង្គការកសិករ ។ល។

### ២.	បញ្ហាប្រឈមក្នុងដំណើរការកែច្នៃ

ជាការពិតការនាំស្រូវចេញមិនទាន់កែច្នៃ គឺជាការខាតបង់តម្លៃបន្ថែមច្រើនសន្ធឹកសន្ធាប់ចំពោះសេដ្ឋកិច្ច។ ប្រសិនបើអាចរក្សាការកែច្នៃក្នុងស្រុកបាន កម្ពុជាអាចចំណេញបាន ចុងអង្ករ កន្ទក់ និង អង្កាម សម្រាប់លើកកម្ពស់សកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត ដូចជា ឧស្សាហកម្មផលិតប្រេងឆា វារីវប្បកម្ម និងការចិញ្ចឹមសត្វ បន្ថែមលើផលចំណេញពីការបង្កើតការងារ និងចំណូលដល់ប្រជាជនដែលពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យនេះ។ ប្រសិនបើមានការវិនិយោគកាន់តែច្រើន លើការបង្កើតរោងម៉ាស៊ីនកិនស្រូវទំនើបៗ នោះកម្ពុជាអាចផលិតអង្ករបានច្រើន និង មានគុណភាពខ្ពស់សម្រាប់ទីផ្សារអន្តរជាតិ ដែលកំពុងតែរីកចម្រើនជាលំដាប់ ព្រមទាំងបង្កើនការទទួលស្គាល់ជាអន្តរជាតិអំពីស្តង់ដារអង្ករកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកំពុងប្រឈមនឹងឧបសគ្គធំៗមួយចំនួន ដែលចាំបាច់ត្រូវដោះស្រាយ ដើម្បីលើកកម្ពស់តម្លៃបន្ថែមក្នុងខ្សែសង្វាក់កែច្នៃអង្ករកម្ពុជា ដូចជា បញ្ហាថ្លៃថាមពល និងថ្លៃដឹកជញ្ជូនខ្ពស់ ព្រមទាំងថ្លៃឥណទានខ្ពស់ និងពិបាកខ្ចី ។ល។

### ៣.	បញ្ហាប្រឈមក្នុងការនាំចេញ និង ទីផ្សារ

ប្រព័ន្ធសម្រួលការនាំចេញ ទាំងផ្នែករឹង និងទន់ នៅមិនទាន់រលូនស៊ីសង្វាក់គ្នា ដែលជាឧបសគ្គចម្បងដល់ការជំរុញនាំចេញអង្ករកម្ពុជា ក្នុងនោះផ្នែករឹងរួមមាន ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន កំពង់ផែ ឃ្លាំងទំនិញ និងផ្នែកទន់ រួមមាន ការសម្រួលពាណិជ្ជកម្ម ស្ថាប័នគាំទ្រ ស្តង់ដារគុណភាព បទដ្ឋានអនាម័យ និងភូតគាមអនាម័យជាដើម ។ល។ បញ្ហាសំខាន់ៗនាពេលបច្ចុប្បន្ន ដែលចាំបាច់ត្រូវដោះស្រាយ រួមមានជាអាទិ៍: ការគាំទ្រផ្នែកស្ថាប័ននៅទន់ខ្សោយ និងភាពពុំមានការទទួលស្គាល់ជាអន្តរជាតិលើគុណភាព និងស្តង់ដារ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែនៅមានកម្រិត។

ទីផ្សារអង្ករ ជាទីផ្សារដែលមានលក្ខណៈគាំពារ និង មានយន្តការស្មុគស្មាញ ទៅតាមលក្ខខណ្ឌ និងតម្រូវការដោយឡែកៗ នៃប្រទេសនាំចូលនីមួយៗ ។ ជាមួយគ្នានេះ ចំពោះកម្ពុជា ការនាំចេញអង្ករគឺជាការងារថ្មី ហើយទាំងបទពិសោធន៍ ទាំងការយល់ដឹង ក៏នៅមានកម្រិតនៅឡើយ ដែលទាមទារឲ្យមានការពង្រឹងសមត្ថភាពនាំចេញ របស់កម្ពុជាទៅកាន់ទីផ្សារទាំងនោះ។

### ក-២ ការលានុភាពភាព

កម្ពុជាមានសក្តានុពលខ្លាំងក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឲ្យបានច្រើន នាពេលខាងមុខ។ យោងតាមការបូកសរុបលទ្ធផលការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរដូវឆ្នាំ ២០១០-២០១១ នេះ បានបង្ហាញថា ផលិតកម្មស្រូវសម្រេចបានចំនួន ៨,២៤ លានតោន ហើយអាចមានអតិរេកផលស្រូវចំនួន ៣,៩ លានតោន សម្រាប់កែច្នៃនាំចេញ។ ប៉ុន្តែកន្លងមក តួលេខនាំចេញផ្លូវការក្នុងឆ្នាំ ២០០៩ មានតែ ១៣ ពាន់តោនអង្ករ ឬ ២០ ពាន់តោនស្រូវប៉ុណ្ណោះ ទោះបីបរិមាណស្រូវជាក់ស្តែងដែលបានហូរចេញពីកម្ពុជា មានកម្រិតខ្ពស់ជាងនេះក្តី។ ប្រការនេះ ឆ្លុះបញ្ចាំងពីសក្តានុពល សម្រាប់ជំរុញការនាំចេញអង្ករជាលក្ខណៈផ្លូវការ ជំនួសឲ្យការនាំចេញស្រូវក្រៅផ្លូវការ ដែលបណ្តាលឲ្យមានការខាតបង់តម្លៃបន្ថែមយ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចជាតិ។

ម៉្យាងវិញទៀត ដោយសារមានការវិនិយោគកាន់តែច្រើន ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងការដាំដុះស្រូវ ការពង្រីកផ្ទៃដីដាំដុះ និង ប្រពលវប្បកម្ម ព្រមទាំងកំណើនទិន្នផលស្រូវ ដោយសារកត្តាប្រើប្រាស់ទឹក ពូជ និង ជី ព្រមទាំងបច្ចេកទេសដាំដុះកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលរំពឹងថានឹងមានការកើនឡើងនូវផលិតកម្មស្រូវ ដែលនាំឲ្យកម្ពុជាកាន់តែមានអតិរេកផលស្រូវ សម្រាប់កែច្នៃជាអង្ករនាំចេញកាន់តែច្រើនឡើងក្នុងពេលខាងមុខ។

## ខ. ចក្ខុវិស័យ និង ទិសដៅយុទ្ធសាស្ត្រ

### ១. ចក្ខុវិស័យ

ឯកសារគោលនយោបាយស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» បានបង្ហាញពីចក្ខុវិស័យ «គឺចង់ឲ្យប្រទេសកម្ពុជា ក្លាយជាជង្រុកស្រូវ និងជាប្រទេសនាំចេញអង្ករសំខាន់មួយលើទីផ្សារពិភពលោក »។ រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ ២០១៥ ជាឆ្នាំគោលដើម្បី: (១)ជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង ៤ លានតោន ក្នុងនោះ បរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេចឱ្យបានយ៉ាងតិច ១ លានតោន និង (២)ធ្វើឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

### ២. ទិសដៅយុទ្ធសាស្ត្រ

ទិសដៅជាយុទ្ធសាស្ត្រ សម្រាប់ការបង្កើនផលិតកម្មដំណាំស្រូវ និងជំរុញការនាំចេញអង្កររបស់កម្ពុជាទៅទីផ្សារអន្តរជាតិគឺសំដៅ "ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈ ការជំរុញផលិតកម្ម ពិសេសប្រពលវប្បកម្មដំណាំស្រូវ ការកែច្នៃ និង សម្រួលពាណិជ្ជកម្ម ដែលនឹងអាចបង្កើនការនាំចេញអង្ករ ពង្រីកទីផ្សារអន្តរជាតិ

បង្កើនតម្លៃបន្ថែម បង្កើនការប្រើប្រាស់ពលកម្មក្នុងស្រុក និងត្រូវធ្វើយ៉ាងណារក្សាបាននូវសន្តិសុខស្បៀងក្នុងប្រទេស និងធានាការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព ″ ។

## គ. អភិក្រម និងគោលការណ៍ប្រតិបត្តិ

អភិក្រម និង គោលការណ៍ប្រតិបត្តិ ត្រូវបានបង្ហាញក្នុងឯកសារគោលនយោបាយ ស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» និងមានខ្លឹមសារសង្ខេបដូចតទៅ៖

### ១. អភិក្រម (Approaches)

**ទី-១៖** សម្រាប់រយៈពេលខ្លី និងបន្ទាន់ខាងមុខ គឺត្រូវជំរុញការផលិតស្រូវដែលមានតម្រូវការទីផ្សារ និងជំរុញការនាំចេញអង្ករ តាមរយៈការបង្វែរការ «***នាំចេញស្រូវក្រៅផ្លូវការ***» ទៅជា «***ការនាំចេញអង្ករផ្លូវការ***»។

**ទី-២៖** សម្រាប់រយៈពេលមធ្យម និងវែង គឺត្រូវផ្តោតទៅលើ «***ការលើកស្ទួយការប្រកួតប្រជែង***» ក្នុងការនាំចេញ តាមរយៈការលើកកម្ពស់បច្ចេកទេសផលិតកម្ម គុណភាព កែច្នៃ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឥណទាន ការសម្រួលពាណិជ្ជកម្ម និងទីផ្សារ។

### ២. គោលការណ៍ប្រតិបត្តិ (Principles)

- ជំរុញការនាំចេញ តាមគោលការណ៍ទីផ្សារសេរី និងការពារផលប្រយោជន៍កសិករ
- លើកទឹកចិត្ត និងគាំទ្រ ការចូលរួមពីកសិករ និង សហគមន៍កសិកម្ម ដើម្បីប្រមូលផ្តុំផលិតកម្ម បង្កើនអំណាចតថ្លៃ
- បង្កើនកិច្ចសហប្រតិបត្តិការ និង ភាពជាដៃគូ រវាងរាជរដ្ឋាភិបាល ជាមួយ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និង ផ្នែកឯកជន
- ប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន ក្នុងការផ្តល់សេវាសាធារណៈ ពាក់ពន្ធ័នឹងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ
- ជំរុញសមត្ថភាពនាំចេញអង្ករដោយខ្លួនឯង ដោយលើកទឹកចិត្តឲ្យក្រុមហ៊ុនប្រមូលទិញ កែច្នៃ រួចនាំចេញជាផ្លូវការ ដោយឈរលើគោលការណ៍ ប្រកួតប្រជែងសុច្ចរិត យុត្តិធម៌ ស្មោះត្រង់ និងគោរពបាននូវកាតព្វកិច្ចបង់ពន្ធ និងកាតព្វកិច្ចផ្សេងៗទៀតរបស់កម្ពុជាជាធរមាន។

ដើម្បីឆ្លើយតបបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ ″ការបង្កើនផលិតភាព ពិសេសប្រពលវប្បកម្មដំណាំស្រូវ″ គឺជាចំណុចគន្លឹះដែលនឹងត្រូវយកចិត្តទុកដាក់ជាអាទិ៍:

- ការបង្កើនសេវាកម្ម និង អន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ តាមរយៈការផ្ទេរបច្ចេកទេសសមស្របដល់កសិករ បង្កើនការស្រាវជ្រាវ និង អភិវឌ្ឍន៍ពូជស្រូវ ដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ និងពិសេសការសម្រិតសម្រាំងពូជស្រូវសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បាន ជំរុញការប្រើប្រាស់ពូជស្រូវ

ទាំងនោះឱ្យបានទូលំទូលាយដល់ស្រទាប់កសិករ រួមជាមួយនឹងការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពខ្ពស់។

- ការប្រមូលផ្តុំផលិតកម្មស្រូវ ក៏ជាចំណុចគ្រឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញ ជាលក្ខណៈទ្រង់ទ្រាយធំ តាមរយៈ "សហគមន៍កសិកម្ម ឬ សហករណ៍កសិកម្ម" ។ ប្រសិនបើផលិតផលស្រូវនៅរាយប៉ាយគ្រប់ទីកន្លែង និងចម្រុះទៅដោយប្រភេទពូជច្រើនមុខនោះ គុណភាពអង្ករពិតជាមិនអាចឆ្លើយតបបាន ទៅនឹងសេចក្តីត្រូវការឡើយ។ ដូចនេះ គឺទាមទារឱ្យមានការប្រមូលផ្តុំផលិតកម្មស្រូវជាចាំបាច់ ហើយសហគមន៍កសិកម្ម គឺជាមជ្ឈមណ្ឌលផលិត និង ផ្គត់ផ្គង់ស្រូវដ៏សំខាន់នាពេលអនាគត។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងត្រូវតម្រង់ទិសនៃការធ្វើអន្តរាគមន៍ ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីផលិតក្នុងទ្រង់ទ្រាយធំនាពេលខាងមុខ។
- ត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ផ្នែកឯកជន ពិសេសបណ្តាក្រុមហ៊ុនដែលចូលរួម ក្នុងការផលិតស្រូវនៅកម្ពុជាផងដែរ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិត ឬសហគមន៍កសិកម្ម និង អ្នកប្រមូលទិញ ដែលជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនប្រមូលទិញ អ្នកនាំចេញ តាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ ក្នុងការសម្រេចបានទិសដៅគោលនយោបាយនេះ។
- ការសម្របសម្រួល និងគាំទ្រវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកិនស្រូវស្របតាមស្តង់ដារទីផ្សារអន្តរជាតិ គឺជាការចាំបាច់ និងត្រូវតែគាំទ្រឱ្យបានខ្លាំងក្លា។
- ការផ្តល់ព័ត៌មានអំពីទីផ្សារតម្លៃ ស្ថានភាពនៃការផ្គត់ផ្គង់ស្រូវ-អង្ករ ។ល។ ក៏ជាមធ្យោបាយដ៏សំខាន់មួយ ដើម្បីឱ្យកសិករ ពាណិជ្ជករ មានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មស្រូវ-អង្ករ នេះ។
- ការសម្រួលពាណិជ្ជកម្ម និងការនាំចេញ តាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទ លិខិតបទដ្ឋាន ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទាក់ទងនឹងការត្រួតពិនិត្យអនាម័យ និង ភូតគាមអនាម័យលើមុខទំនិញកសិផល ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យ និង ភូតគាមអនាម័យ គឺជាវិធានការចាំបាច់ និងត្រូវពង្រឹងបន្ថែមទៀត។ សកម្មភាពជាច្រើន ដែលពាក់ព័ន្ធផ្នែកនេះ នឹងត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពលំអិត ពិសេសការផ្តោតជាសំខាន់ ទៅលើការពង្រឹងសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ ពង្រឹងសមត្ថភាពវាយតម្លៃ និងទប់ស្កាត់ហានិភ័យ អនាម័យ និង ភូតគាមអនាម័យ ការរៀបចំកសាង និង ការពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានា ឱ្យមានប្រសិទ្ធភាព ដោយត្រូវរៀបចំសម្រួលនីតិវិធីនៃការនាំចេញ ឱ្យមានភាពសាមញ្ញ ឆាប់រហ័ស និងចំណាយថវិកាតិច ។

# ផ្នែកទី ២

## ផែនការសកម្មភាពសម្រាប់អនុវត្តឯកសារគោលនយោបាយ ស្តីពី "ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ"

ឯកសារគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលបានដាក់ចេញនេះ គឺជាត្រីវិស័យចង្អុលផ្លូវមួយដ៏សំខាន់ ដើម្បីណែនាំតម្រង់ទិស ឱ្យគ្រប់ភាគីពាក់ព័ន្ធក្នុងផលិតកម្ម និង អាជីវកម្មស្រូវ-អង្ករនេះអនុវត្ត សំដៅជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ មានសន្ទុះលឿន ទៅមុខស្របតាមនិន្នាការរីកចំរើននៃទីផ្សារសកល។

សូចនាករកំណត់ក្នុងទិសដៅនៃគោលនយោបាយនេះ គឺធ្វើយ៉ាងណាឱ្យកម្ពុជា មានផលិតផលស្រូវដែលផលិតលើស ប្រមាណជាង ៤ លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង ១លានតោន នៅឆ្នាំ ២០១៥ ដែលនេះ ទាមទារឱ្យគ្រប់ស្ថាប័ន ក្រសួងជំនាញពាក់ព័ន្ធ ត្រូវតែចាត់វិធានការសមស្រប និងបន្ទាន់ ដើម្បីសម្រេចបាននូវគោលដៅនេះ ហើយជាពិសេសទៀតនោះគឺ មជ្ឈដ្ឋានកសិករត្រូវតែកែប្រែទម្លាប់ ពីជាកសិករផលិតគ្រប់ហូបចុក មកជាអ្នកផលិតដើម្បីធ្វើជំនួញផលិតផលវិញ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលំអិតរបស់ខ្លួន សំដៅឆ្លើយតប និង សម្រេចបាននូវទិសដៅគោលនយោបាយ ដែលបានកំណត់នេះ និងបានធ្វើកិច្ចការនេះយ៉ាងហ្មត់ចត់ ដោយតម្រូវឱ្យគ្រប់នាយដ្ឋានពាក់ព័ន្ធ ពិនិត្យ និងពិចារណារ នូវសកម្មភាព ដែលនឹងត្រូវអនុវត្ត ហើយឆ្លើយតបនឹងទិសដៅគោលនយោបាយនេះ។

### I- ផែនការសកម្មភាព

### ១.១ វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវ

#### ក. វិធានការបន្ទាន់

<u>វិធានការគោលនយោបាយ</u>៖ *សម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ជាតុចូលកសិកម្ម និងគ្រឿងយន្តកសិកម្ម*

<u>សកម្មភាព</u>៖

- រៀបចំកែលម្អនីតិវិធីជួយសម្របសម្រួលការធ្វើអាជីវកម្ម ការចុះបញ្ជិកា និងការនាំចូលសម្ភារកសិកម្ម ។ ព័ត៌មានបង្ហាញផ្លូវសម្រាប់អតិថិជន ស្តីពីការកែសម្រួលនីតិវិធីក្នុងការធ្វើអាជីវកម្ម ការចុះបញ្ជិកា និងការនាំចូលសម្ភារកសិកម្ម នឹងត្រូវបានកំណត់ច្បាស់លាស់ និងដាក់ឲ្យប្រើប្រាស់។

<u>**វិធានការគោលនយោបាយ**</u>៖ *«បន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធ លើការនាំចូលចំពោះសម្ភារ និង បរិក្ខារទាំងនោះ»*

<u>សកម្មភាព</u>៖ រៀបចំបញ្ជីឈ្មោះគ្រឿងយន្តកសិកម្ម ដើម្បីសម្របសម្រួលការនាំចូល។

<u>**វិធានការគោលនយោបាយ**</u>៖ *ផ្តល់ការលើកទឹកចិត្តដល់ផលិតករ និងការបែងចែកពូជក្នុងស្រុក:*

*១- កំណត់ប្រភេទពូជស្រូវសំខាន់ៗមួយចំនួន ដែលជាគោលដៅអាទិភាពជំរុញផលិតកម្ម និងការផ្សព្វផ្សាយប្រើប្រាស់ពូជឲ្យបានស្រេចបាច់ នៅមុនដំណាច់ឆ្នាំ ២០១០ នេះ និងរៀបចំក្របខណ្ឌ័គតិយុត្ត និងយន្តការដើម្បីលើកស្ទួយដល់ផលិតកម្ម និងការបែងចែកផ្សព្វផ្សាយប្រើប្រាស់ពូជ ឲ្យបានស្រេចបាច់នៅមុនបំណាច់ឆ្នាំ ២០១០ នេះដែរ ។*

<u>សកម្មភាព</u>៖

១.១- កំណត់ប្រភេទពូជស្រូវសំខាន់ៗមួយចំនួន ដែលសមស្របសម្រាប់ប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ មានសក្តានុពលទិន្នផលខ្ពស់ និងមានគុណភាពស្របតាមតម្រូវការទីផ្សារជាតិ និងអន្តរជាតិ។ ពូជស្រូវយ៉ាងតិចបំផុតចំនួន ១០ពូជត្រូវបានកំណត់ជាបឋម ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សកម្មភាពនេះបានអនុវត្តរួច) ។

១.២- សិក្ខាសាលាពិគ្រោះយោបល់ លើប្រភេទពូជស្រូវមួយចំនួន ជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធ (សកម្មភាពនេះបានអនុវត្តរួច) ។

១.៣- រៀបចំសារាចរណែនាំឱ្យប្រើប្រាស់ពូជស្រូវ ដែលបានកំណត់រួច និង ផ្សព្វផ្សាយឲ្យបានទូលាយ ។

១.៤- ចងក្រង និងបោះពុម្ពសៀវភៅ ស្តីអំពីលក្ខណៈពូជស្រូវ ដែលបានកំណត់ រួមទាំងវិធីសាស្ត្រសម្រិតសម្រាំងពូជស្រូវតាមបែបកសិករ ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ជី និងលក្ខខណ្ឌក្សេត្របរិស្ថានដំណាំស្រូវ។

១.៥- ចងក្រង និងបោះពុម្ពផ្សព្វផ្សាយ សៀវភៅបង្កុំបច្ចេកទេស បង្កើនផលិតភាពដំណាំស្រូវ (Technology Package for Increased Rice Productivity=TPIRP) សម្រាប់ប្រភេទ ឬក្រុមនៃពូជស្រូវ ដែលបានកំណត់ឲ្យប្រើប្រាស់។ សៀវភៅចំនួន ៥.០០០ ច្បាប់ យ៉ាងតិច ត្រូវបានបោះពុម្ព និងចែកចាយជូនអង្គភាពជំនាញ មន្ទីរកសិកម្មរាជធានី-ខេត្ត ការិយាល័យកសិកម្មស្រុក ក្រុមប្រឹក្សាឃុំ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ។

១.៦- បើកវគ្គបណ្តុះបណ្តាលគ្រូជំនាញ (Master trainers) ចំនួន ០២ វគ្គ ដោយផ្តោតលើ (១) លក្ខណៈសំខាន់ៗ របស់ពូជស្រូវទាំង១០ (២) វិធីសាស្ត្រសម្រិត

សម្រាំងពូជស្រូវតាមបែបកសិករ (៣)ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ដី (៤)លក្ខខណ្ឌក្សេត្របរិស្ថានដំណាំស្រូវ និង (៥)បង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ ដើម្បីឲ្យមន្ត្រីទាំងនោះក្លាយជាគ្រូជំនាញ សម្រាប់បណ្តុះបណ្តាលគ្រូបង្គោលបន្តទៀត។

១.៧- រៀបចំកែសម្រួល និងបោះពុម្ពឯកសារ ស្តីពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវរបស់ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ឲ្យស្របតាមសមត្ថភាពរបស់គ្រូបង្គោល។ ឯកសារកែសម្រួលសម្រាប់គ្រូបង្គោលអំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវចំនួន ៥.០០០ ច្បាប់ នឹងត្រូវបានបោះពុម្ព និងបែងចែក។

១.៨- បណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីចំនួន ១.៥០០នាក់ តាមបណ្តាខេត្តចំនួន ១០ អំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ និងបច្ចេកទេសការពារដំណាំស្រូវ ដែលរួមមាន សមាសភាពចង្រៃ និងវិធានការកំចាត់ ។

១.៩- បើកវគ្គបណ្តុះបណ្តាលកសិករចំនួន ២៥.០០០នាក់ ក្នុងខេត្តចំនួន ១០ ស្តីពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ និង ពិសេសផ្តោតលើសមាសភាពចង្រៃ និងវិធានការកំចាត់ សំដៅជួយដល់ការបង្កើនផលិតកម្ម ដំណាំស្រូវ។

១.១០- ធ្វើស្រែបង្ហាញចំនួន ៥០០ កន្លែង ដើម្បីណែនាំកសិករ អំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ វិធានការកំចាត់សមាសភាពចង្រៃ តាមតំបន់ស្រោចស្រព ។

១.១១- ផលិតគ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវដែលបានកំណត់ចំនួន ៥ ហិកតា តាមរយៈគម្រោង Community Based Agricultural Productivity Project (CBAPP) និង ២ ហិកតា តាមរយៈថវិការាជរដ្ឋាភិបាល ២០១១ សម្រាប់ចែកចាយជូនប្រជាកសិករគម្រោង CBAPP និងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់ ក្នុងឆ្នាំ ២០១១ និង ២០១២។ គ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវដែលបានកំណត់ចំនួន ១០.៥០០ គ.ក្រ ត្រូវបានផលិត និងប្រើប្រាស់ដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ។

១.១២- ផលិតគ្រាប់ពូជសុទ្ធទទួលស្គាល់ របស់ពូជស្រូវដែលបានកំណត់ លើផ្ទៃដីចំនួន ៥ ហិកតា (៨.៥០០ គ.ក្រ) សម្រាប់ចែកចាយ និងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់ក្នុងឆ្នាំ ២០១១ និង ២០១២ (CARDI)។

១.១៣- ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាត នៅតាមស្ថានីយ៍លើកដំបូងលើផ្ទៃដី ៥០ ហិកតា ។ គ្រាប់ពូជចំនួន ១៥០ តោន នឹងត្រូវបានផលិត ដោយបណ្តាស្ថានីយ៍នានារបស់អគ្គនាយកដ្ឋានកសិកម្ម និងធ្វើការផ្សព្វផ្សាយឱ្យកសិករប្រើប្រាស់។

១.១៤- ផលិតគ្រាប់ពូជសុទ្ធល្អនៅតាមស្ថានីយ៍ និង សហគមន៍កសិករ លើផ្ទៃដី៤៥០ ហិកតា ។ គ្រាប់ពូជសុទ្ធល្អចំនួន ១.៣៥០តោន ត្រូវបានផលិតនិងផ្គត់ផ្គង់ជូនកសិករក្នុងតំបន់គោលដៅ ។

១.១៥- បោះពុម្ពឯកសារបច្ចេកទេស ស្តីពី ផលិតកម្មគ្រាប់ពូជសុទ្ធល្អ ចំនួន ១០.០០០ ច្បាប់ និងរៀបចំកម្មវិធីផ្សព្វផ្សាយដល់កសិករ។

១.១៦- បណ្តុះបណ្តាលសហគមន៍កសិករ ចំនួន ១.៦០០ នាក់ នៅ ២០ សហគមន៍ ស្តីពី បច្ចេកទេសផលិតកម្មគ្រាប់ពូជសុទ្ធល្អ។

១.១៧- រៀបចំគោលការណ៍ យន្តការអនុវត្ត និងឯកសារវាយតម្លៃ និងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ។

១.១៨- គ្រោងស្តុក និងផ្តល់ឥណទានស្រូវពូជមានគុណភាពខ្ពស់ប្រចាំឆ្នាំ សម្រាប់ត្រៀមការស្តារការខូចខាត ដោយគ្រោះធម្មជាតិទឹកជំនន់ និងគ្រោះរាំងស្ងួតតាមបណ្តារាជធានី-ខេត្ត។ ស្រូវពូជយ៉ាងតិចចំនួន ១.០០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារ ត្រូវបានផ្តល់ជូនកសិករខ្ចីប្រើប្រាស់រៀងរាល់ឆ្នាំ សម្រាប់ស្តារការខូចខាតដោយគ្រោះធម្មជាតិ។

១.១៩- ត្រៀមស្រូវពូជអន្តរាគមន៍សង្គ្រោះបន្ទាន់ប្រចាំឆ្នាំ សម្រាប់ការស្តារការខូចខាតដោយគ្រោះធម្មជាតិទឹកជំនន់ និងគ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត។ ស្រូវពូជចំនួន ៥០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារ ត្រូវបានចែកជូនកសិករប្រើប្រាស់រៀងរាល់ឆ្នាំ ដើម្បីស្តារការខូចខាតដោយគ្រោះធម្មជាតិ ។

__វិធានការគោលនយោបាយ៖__

២- *ពង្រឹងនិងពង្រីកសមត្ថភាព វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា* (CARDI) *ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម កសិដ្ឋានសម្រាប់ផលិតពូជ សិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាលបច្ចេកទេស។*

__សកម្មភាព៖__

២.១- សិក្សា និងរៀបចំផែនការលំអិត ដើម្បីពង្រឹងនិងពង្រីក កសិដ្ឋាន ស្ថានីយ៍ និង មណ្ឌលអភិវឌ្ឍន៍ សំរាប់ផលិតកម្មពូជស្រូវ។ ផែនការសកម្មភាព និង ការចំណាយលំអិតនៅស្ថានីយ៍ ០៧ ត្រូវបានសិក្សា និងរៀបចំ ។

២.២ ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាជំហានដំបូង នៅកសិដ្ឋានផលិតពូជស្រូវទួលសំរោង ដើម្បីគាំទ្រដល់ការផលិតពូជ (តាមរយៈគំរោង ADB Emergency Food Assistance) ។

២.៣ រៀបចំកែលំអឯកសារ និងផែនការពិសោធន៍ស្រាវជ្រាវ បន្សាំតាមប្រភេទប្រពន្ធ័អេកូឡូស៊ីរបៀបរៀបស្ថានផ្សេងៗ ។ ឯកសារ និងផែនការពិសោធន៍ស្រាវជ្រាវ ត្រូវបានរៀបចំជាថ្មី ។

២.៤ កំនត់តំបន់ផលិតកម្មស្រូវ ដែលមានប្រភពទឹក និងប្រពន្ធ័ធារាសាស្រ្ត ។

២.៥ រៀបចំចងក្រង និងបោះពុម្ពផ្សព្វផ្សាយអត្ថបទបច្ចេកទេស ស្តីពីសមាសភាពចង្រៃ (សត្វល្អិតចង្រៃ ជំងឺ និងស្មៅចង្រៃ) លើដំណាំស្រូវ និងថ្នាំកសិកម្ម និងការប្រើប្រាស់ យ៉ាងតិចចំនួន ១០.០០០ ច្បាប់។

២.៦ តំបន់គ្មានសមាសភាពចង្រៃលើដំណាំស្រូវ ចំនួន ២ ត្រូវបានកំណត់ ដើម្បីសម្របសម្រួលការធ្វើពាណិជ្ជកម្មអង្ករទៅកាន់ទីផ្សារអន្តរជាតិ។

២.៧ សិក្សាពីប្រភេទសមាសភាពចង្រៃលើដំណាំស្រូវ នៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រង និងផ្សព្វផ្សាយអត្ថបទបច្ចេកទេស ស្តីពី សត្វល្អិតចង្រៃលើដំណាំស្រូវ ចំនួន ៥.០០០ច្បាប់។

២.៨ ត្រៀមថ្នាំកសិកម្ម និងឧបករណ៍ សម្រាប់អន្តរាគមន៍បន្ទាន់ ក្នុងការកំចាត់សមាសភាពចង្រៃ នៅពេលមានការផ្ទុះឡើងការបំផ្លាញ ដើម្បីធានាថាគ្មានការបាត់បង់ទិន្នផល បើទោះបីមានការបំផ្លាញក៏ដោយ។

២.៩ បំពាក់ឧបករណ៍កសិកម្មតាមរយៈគម្រោង CBAPP នូវត្រាក់ទ័រចំនួន ០១ គ្រឿង និង mini-combined harvester ចំនួន ០១ គ្រឿង និងគម្រោងស្រោចស្រពនិងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើត នូវត្រាក់ទ័រចំនួន ០៣ គ្រឿង និងគ្រឿងបរិក្ខាភ្ជួររាស់ចំនួន ០៣ សម្រាប់ រួមទាំងម៉ាស៊ីនបោកស្រូវចំនួន ០១ គ្រឿង និងម៉ាស៊ីនបូមទឹកដើរដោយចរន្តអគ្គីសនី រោងនិងបណ្តាញខ្សែភ្លើងត្រូវបានបំពាក់នៅស្រះទឹកចំនួន ០៤ នៅក្នុងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។

២.១០ បំពាក់ឧបករណ៍មន្ទីរពិសោធន៍គ្រាប់ពូជ ក្នុងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងបណ្តុះបណ្តាលមន្ត្រីឲ្យចេះប្រើប្រាស់ តាមរយៈគម្រោង CBAPP ។

២.១១ ចង់ប្លាស្ទីក Volcanic cube (cocune) សំរាប់ចំណុះ ៣ តោន ចំនួន ១០ សម្រាប់ចំណុះ ៥ តោន ចំនួន ៣ និងសំរាប់ចំណុះ ១០ តោន ចំនួន ២ សម្រាប់ទុកគ្រាប់ពូជស្រូវ នឹងត្រូវបានផ្តល់ជូន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ។

<u>វិធានការគោលនយោបាយ៖</u>

៣- *ពិនិត្យឡើងវិញនូវក្របខ័ណ្ឌ នៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម* (Extension Services)។

<u>សកម្មភាព</u>៖ ពាក់ព័ន្ធនឹងការពិនិត្យឡើងវិញ នូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម (Extension Services) ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានសកម្មភាពមួយចំនួនដូចខាងក្រោម៖

៣.១ សិក្សាវាយតម្លៃស្ថានភាពបច្ចុប្បន្ន លើប្រព័ន្ធនិងសេវាផ្សព្វផ្សាយកសិកម្ម។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅតាមបណ្តាខេត្តទាំង ១០ នឹងត្រូវបានធ្វើការវាយតម្លៃ។ របាយការណ៍វាយតម្លៃមួយ ត្រូវបានរៀបចំ និងចងក្រងជាឯកសារ ។

៣.២ រៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្ម។ របាយការណ៍វាយតម្លៃមួយត្រូវបានរៀបចំ និងចងក្រងជាឯកសារ និងគោលការណ៍តាមដាននិងវាយតម្លៃ គុណភាពសេវាផ្សព្វផ្សាយកសិកម្ម ត្រូវបានរៀបចំឡើង។

## ខ. វិធានការរយៈពេលមធ្យមនិងវែង

<u>វិធានការគោលនយោបាយ (៤)</u>៖

- *រៀបចំផែនការគ្រប់គ្រងទឹករយៈពេល១០-២០ឆ្នាំ និងដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែង*
- *កំណត់យកការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក ជាអាទិភាពសំខាន់របស់រាជរដ្ឋាភិបាល*

<u>សកម្មភាព</u>៖

៤.១- ធ្វើការអង្កេតសេដ្ឋកិច្ចគ្រួសារមុន និងក្រោយធ្វើវិនិយោគប្រព័ន្ធធារាសាស្ត្រ ដើម្បីប្រៀបធៀបការរីកចំរើនរបស់កសិករ ក្នុងតំបន់កសាងប្រពន្ធ័ធារាសាស្ត្រ ។

៤.២- កំណត់រកប្រព័ន្ធដំណាំដោយយកដំណាំស្រូវជាមូលដ្ឋាន តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើត នៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ។ ប្រព័ន្ធដំណាំដោយយកដំណាំស្រូវជាមូលដ្ឋានចំនួន ៤៥ កន្លែង នឹងត្រូវបានចូលរួមវាយតម្លៃដោយកសិករចំនួន ១.០០០ នាក់។

៤.៣- បញ្ជ្រាបការបញ្ចូលស្រូវពូជទាំង ១០ តាមរយៈការដឹកនាំកសិករផលិត និងសម្រិតសម្រាំងគ្រាប់ពូជស្រូវ តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើត នៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ។

៤.៤- បង្ហាញនូវបង្គុំបច្ចេកវិទ្យាបង្កើនផលិតភាពដំណាំស្រូវ តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើត នៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ។ កសិករគម្រូចំនួន ៧៥ នាក់នឹងចេះអនុវត្ត និងកសិករចំនួន ២.២០០ នាក់ទៀត ត្រូវបានយល់ដឹងអំពីបច្ចេកវិទ្យាបង្កើននូវផលិតភាពដំណាំស្រូវ។

**<u>វិធានការគោលនយោបាយ៖</u>**

*៥-បង្កើនការវិនិយោគលើការស្តារឡើងវិញ នូវស្ថានីយ៍ មណ្ឌលអភិវឌ្ឍន៍ និងកសិដ្ឋាន ដើម្បីបម្រើការងារស្រាវជ្រាវអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាគាំទ្រដល់ផលិតកម្មកសិកម្ម។*

<u>សកម្មភាព៖</u>

៥.១- ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថានីយ៍ ចំនួន៧ របស់ អគ្គនាយកដ្ឋានកសិកម្ម ត្រូវបានជួសជុលឲ្យដំណើរការល្អឡើងវិញ។

៥.២- បំពាក់ឧបករណ៍ និងបរិក្ខាចាំបាច់ សម្រាប់គាំទ្រការស្រាវជ្រាវ និងផ្ទេរបច្ចេកវិជ្ជាផលិតកម្មដំណាំស្រូវ នៅតាមស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម ។

៥.៣- ជួសជុលនិងសាងសង់មជ្ឈមណ្ឌលសំរាប់បណ្តុះបណ្តាលមន្ត្រីជំនាញ អ្នកផ្សព្វផ្សាយ និងកសិករនៅស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម។

៥.៤- ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាត នៅតាមបណ្តាស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម។ គ្រាប់ពូជសុទ្ធអនុញ្ញាត ៤.៨០០ តោន លើផ្ទៃដី ១.៦០០ ហ.ត ត្រូវបានផលិត និងផ្គត់ផ្គង់ជូនសហគមន៍កសិករ ដើម្បីផលិតគ្រាប់ពូជសុទ្ធល្អ ។

៥.៥- ធ្វើពិសោធន៍ស្រាវជ្រាវ ច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ ចំនួន ៨០០ ពិសោធន៍ នៅស្ថានីយ៍ កសិដ្ឋាន និង មណ្ឌលអភិវឌ្ឍន៍កសិកម្ម។

៥.៦- ពង្រីកការបណ្តុះបណ្តាលកសិករ អំពីច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ។ កសិករ ៦០.០០០នាក់ ត្រូវបានបណ្តុះបណ្តាល ២០០វគ្គ ក្នុង១០ខេត្ត រយៈពេល ៤ ឆ្នាំ។

៥.៧- ពង្រីកការបណ្តុះបណ្តាលកសិករ ២.៤០០ នាក់ អំពីផលិតកម្មពូជសុទ្ធល្អ នៅតាមសហគមន៍កសិកម្មចំនួន៨០ ។

៥.៨- ចុះពិនិត្យនិងផ្តល់ជំនួយបច្ចេកទេស ក្នុងការផលិតពូជសុទ្ធល្អ នៅតាមសហគមន៍ និង ក្រុមហ៊ុន ដើម្បីចែកចាយធ្វើផលិតកម្ម។

៥.៩- ចុះសិក្សា និង វាយតម្លៃបន្ថែម អំពីពូជស្រូវដែលឆ្លើយតបនឹងទីផ្សារ។ ប្រភេទពូជដែលឆ្លើយតបនឹងទីផ្សារ ត្រូវបានវាយតម្លៃនិងកំណត់បន្ថែមនៅ១០ខេត្ត។

៥.១០- ពង្រីកការធ្វើស្រែបង្ហាញអំពីបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវតាមសហគន៍។ ស្រែបង្ហាញចំនួន ៣.០០០ កន្លែងត្រូវបានអនុវត្ត (៥ឆ្នាំ) ។

៥.១១- រៀបចំសិក្ខាសាលាផ្សព្វផ្សាយបច្ចេកទេសប្រចាំឆ្នាំ ដើម្បីចែករំលែកបទពិសោធន៍ល្អៗ ក្នុងប្រពលវប្បកម្មដំណាំស្រូវ។

៥.១២- រៀបចំទស្សនៈកិច្ចសិក្សាក្នុងប្រទេសចំនួន ១០០ ដល់កសិករ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ល្អៗ ក្នុងការធ្វើផលិតកម្មដំណាំស្រូវ។

៥.១៣- រៀបចំទស្សនៈកិច្ចសិក្សាក្រៅប្រទេសចំនួន ២០ សំរាប់មន្ត្រីបច្ចេកទេស ដើម្បីផ្លាស់ប្តូរបទពិសោន៍ និងទទួលបានចំណេះដឹងចំណេះធ្វើថ្មីៗ ក្នុងរយៈពេល ៥ឆ្នាំខាងមុខ។

៥.១៤- ផលិតឧបករណ៍កសិកម្ម និងគ្រឿងយន្តកសិកម្មសាកពិសោធន៍ សម្រាប់ការរៀបចំដីដាំដុះ។

៥.១៥- រៀបចំធ្វើបង្ហាញអំពីប្រសិទ្ធភាពឧបករណ៍ និងគ្រឿងយន្តកសិកម្ម ដែលបានផលិតដើម្បីជួយកសិករ ក្នុងការប្រើប្រាស់សំដៅបង្កើនផលិតភាព ប្រពលវប្បកម្មដំណាំស្រូវ។ កសិករ ១.២៥០ នាក់ យ៉ាងតិច នឹងត្រូវបានចូលរួម និងទទួលចំណេះដឹងទាំងនេះ។

៥.១៦- បើកវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាក្រោយពេលប្រមូលផលស្រូវ។ វគ្គបណ្តុះបណ្តាលចំនួន ៥០០វគ្គ មានកសិករចូលរួមចំនួន ១៧.៥០០ នាក់ នឹងត្រូវបានរៀបចំ ។

៥.១៧- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់កសិករចំនួន ៧.៥៦០នាក់ អំពីការថែទាំជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ។

៥.១៨- ត្រៀមថ្នាំកសិកម្ម និងឧបករណ៍សំរាប់អន្តរាគមន៍បន្ទាន់ ដើម្បីកំចាត់សមាសភាពចង្រៃនៅពេលមានការផ្ទុះឡើងការបំផ្លាញ។ ដំណាំស្រូវប្រមាណ ៦០.០០០ ហិកតាក្នុងរយៈពេល០៥ឆ្នាំ ដែលទទួលរងការបំផ្លាញត្រូវបានការពារ ។

៥.១៩- សង់ប្រឡាយបេតុងរំដោះទឹក ស្តារប្រឡាយក្នុងបរិវេណវិទ្យាស្ថាន និងជីកប្រឡាយនាំទឹកពីប្រឡាយទឹកខាងលិចមកប្រឡាយក្នុង វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។

៥.២០- គ្រោងស្តុក និងផ្តល់ឥណទានស្រូវពូជ មានគុណភាពខ្ពស់ប្រចាំឆ្នាំ សម្រាប់ត្រៀមការស្តារការខូចខាតដោយគ្រោះធម្មជាតិទឹកជំនន់ និងគ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត។ ស្រូវពូជចំនួន ១.០០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារត្រូវបានផ្តល់ជូនកសិករខ្ចីប្រើប្រាស់រៀងរាល់ឆ្នាំ សម្រាប់ស្តារការខូចខាត ដោយគ្រោះធម្មជាតិ ។

៥.២១- ត្រៀមស្រូវពូជអន្តរាគមន៍សង្គ្រោះបន្ទាន់ ប្រចាំឆ្នាំសម្រាប់ការស្តារការខូចខាត ដោយគ្រោះធម្មជាតិទឹកជំនន់ និង គ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត។ ស្រូវពូជចំនួន

៥០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារ ត្រូវបានចែកជូនកសិករប្រើប្រាស់រៀងរាល់ឆ្នាំ ដើម្បីស្តារការខូចខាតដោយគ្រោះធម្មជាតិ។

៥.២២- សាងសង់ឃ្លាំងសម្រាប់ស្តុកស្រូវពូជ តាមស្តង់ដារបច្ចេកទេសត្រឹមត្រូវ (ចំនួន១៧) នៅតាមបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ទាំង ១៧ ដើម្បីរក្សាគុណភាពដំណុះស្រូវពូជ និង ធានានូវបរិមាណស្រូវពូជ ដែលនឹងត្រូវធ្វើអន្តរាគមន៍។

<u>វិធានការគោលនយោបាយ</u>៖ *៦-ពង្រីករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម ដល់ថ្នាក់ឃុំ។*

<u>សកម្មភាព</u>៖

៦.១- ការរៀបចំរចនាសម្ព័ន្ធ តួនាទីភារកិច្ចមណ្ឌលកសិកម្មឃុំសង្កាត់៖

- ✓ ចុះសិក្សា និងប្រមូលព័ត៌មាន សម្រាប់រៀបចំរចនាសម្ព័ន្ធ របស់មណ្ឌលកសិកម្មចំណុះការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ និងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្ម ឃុំ សង្កាត់
- ✓ រៀបចំសេចក្តីព្រាងតួនាទី ភារកិច្ចរបស់មណ្ឌល កសិកម្ម ឃុំ សង្កាត់
- ✓ រៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅតំបន់គោលដៅ ចំនួន០៤
- ✓ រៀបចំសិក្ខាសាលាថ្នាក់ក្រសួង ដើម្បីពិនិត្យ និង សម្រេច លើសេចក្តីព្រាងរចនាសម្ព័ន្ធ និងតួនាទីភារកិច្ច របស់មណ្ឌលកសិកម្ម ឃុំ សង្កាត់ ។

៦.២- ការពង្រាយមន្ត្រីរាជការឲ្យដល់មូលដ្ឋានមណ្ឌលកសិកម្ម ឃុំសង្កាត់៖

- ✓ រៀបចំសិក្ខាសាលាថ្នាក់កណ្តាល និងរាជធានីខេត្ត ដើម្បីពិគ្រោះយោបល់ រកវិធីសាស្រ្ត និងតំរូវការមន្ត្រីរាជការ
- ✓ រៀបចំសារាចរណែនាំដល់មន្ទីរកសិកម្មរាជធានី-ខេត្ត ដើម្បីជំរុញមន្ត្រីរាជការដែលមានស្រាប់ក្នុងមន្ទីរកសិកម្ម ឲ្យបំពេញការងារដល់មណ្ឌលកសិកម្ម ឃុំសង្កាត់
- ✓ រៀបចំផែនការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី។

៦.៣- ការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីមូលដ្ឋាន៖

- ✓ រៀបចំវគ្គបណ្តុះបណ្តាលលើការងាររដ្ឋបាលគ្រប់គ្រង ការរៀបចំផែនការការងារគណនេយ្យ ចំនួន២៤ វគ្គ
- ✓ ពង្រាយមន្ត្រីរាជការដល់មណ្ឌលកសិកម្មឃុំសង្កាត់
- ✓ សាងសង់មណ្ឌលកសិកម្មនៅតាមឃុំសង្កាត់។

៦.៤- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក ។

៦.៥- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មឃុំ និង ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ។

**<u>វិធានការគោលនយោបាយ (៧)៖</u>**

- *រៀបចំគម្រោងផែនការ ដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធអង្គការកសិករ*
- *ពង្រឹងតួនាទីរបស់រចនាសម្ព័ន្ធអង្គការកសិករ ដើម្បីធ្វើការសម្របសម្រួលដោះស្រាយបញ្ហាផលិតកម្ម តម្រូវការ និងកង្វល់នានារបស់កសិករ។*

**<u>សកម្មភាព៖</u>**

៧.១- ចងក្រងក្រុមកសិករឲ្យទៅជាសហាគមន៍កសិកម្ម។ សហាគមន៍កសិកម្ម ១៣០ ត្រូវបានបង្កើតឡើងនៅតាមខេត្តគោលដៅ។

៧.២- ធ្វើសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនាំស្រូវចេញរបស់រដ្ឋាភិបាល ដល់សហ-គមន៍កសិកម្ម។ សហាគមន៍កសិកម្មចំនួន ១៣០ នៅក្នុងខេត្តគោលដៅទាំង១០ នឹងយល់ដឹងអំពីគោលនយោបាយនាំស្រូវចេញរបស់រាជរដ្ឋាភិបាល។

៧.៣- រៀបចំចងក្រងបណ្តាញសហាគមន៍កសិកម្ម ។

៧.៤- រៀបចំសហាគមន៍កសិកម្ម ចំនួន ១៣០ នៅខេត្តគោលដៅចំនួន១០។

៧.៥- រៀបចំធ្វើសិក្ខាសាលាបំពាក់បំប៉នអំពីជំនួញស្រូវអង្ករ ដល់សហាគមន៍កសិកម្ម ចំនួន ១៣០។

៧.៦- រៀបចំចងក្រងបណ្តាញធូរកិច្ចសហាគមន៍កសិកម្មនៅថ្នាក់ជាតិ និងតាមខេត្តគោលដៅ ចំនួន ១៣ បណ្តាញ។

**<u>វិធានការគោលនយោបាយ៖</u>**

*៨-លើកកម្ពស់សមត្ថភាពរបស់កសិករ និងសហាគមន៍កសិកម្ម ក្នុងការខ្ចីនិងការប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។*

**<u>សកម្មភាព៖</u>**

៨.១- ពង្រឹងសមត្ថភាពសហាគមន៍កសិកម្ម លើការងារដឹកនាំ និងរដ្ឋបាល ការគ្រប់គ្រងបញ្ជីគណនេយ្យសហាគមន៍ និង ផែនការមុខជំនួញ។ ថ្នាក់ដឹកនាំសហាគមន៍និងហិរញ្ញឹកចំនួន ៨០០ នាក់យល់ដឹងអំពីការគ្រប់គ្រងគណនេយ្យ ភាពជាអ្នកដឹកនាំ និង ការងាររដ្ឋបាល ថ្នាក់ដឹកនាំ និង កសិករសហាគមន៍ចំនួន ១.៦០០ នាក់ យល់ដឹងអំពីការផែនការមុខជំនួញ និងក្រុមសន្សំប្រាក់ចំនួន ៦០ របស់សហាគមន៍ត្រូវបានបង្កើតឡើង ។

៨.២- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសហាគមន៍ ដើម្បីគាំទ្រដល់សហាគមន៍កសិកម្ម ។ សហាគមន៍កសិកម្មចំនួន ២០ នឹងទទួលបានសេវាកម្មគាំទ្រលើការសម្ងួត និងឃ្លាំងស្តុកទុកស្រូវ ។

៨.៣- ពង្រឹងសហគមន៍កសិកម្មលើការងារគ្រប់គ្រងបញ្ជីបេឡា និងការធ្វើជំនួញកសិកម្ម។ អ្នកដឹកនាំ និងបេឡាសហគមន៍កសិកម្ម ចំនួន ៩១០ នាក់ នឹងបង្កើនបាននូវសមត្ថភាពគ្រប់គ្រងការងារបេឡា និងការធ្វើផែនការជំនួញ ។

៨.៤- កសាងឡសម្ងួត និងឃ្លាំងស្តុកកសិផល (ស្រូវ) ដល់សហគមន៍ចំនួន ២០ ។

<u>វិធានការគោលនយោបាយ៖</u>

*៩-រៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដី និងផ្សព្វផ្សាយឲ្យបានទូលាយ។*

<u>សកម្មភាព៖</u>

៩.១- ចាត់ថ្នាក់ និងវាយតម្លៃភាពសមស្របនៃដីសម្រាប់ដំណាំកសិកម្ម តាមរយៈ សិក្សាស្រាវជ្រាវជាមូលដ្ឋាន ក្នុងការប្រមូលផ្តុំទិន្នន័យដែលមានកន្លងមក ពាក់ពន្ធ័នឹងការវាយតម្លៃប្រភេទដីសម្រាប់ដំណាំកសិកម្ម ព្រមទាំងផ្ទៀងផ្ទាត់តាមរយៈចុះអង្កេតផ្ទាល់ដល់ទីវាលជាក់ស្តែង ដើម្បីរៀបចំគូរព្រំប្រទល់ដី ចុះសិក្សាអង្កេត និងវាយតម្លៃពីលក្ខណៈរបស់ដី និងសក្តានុពលរបស់ដី ដើម្បីកំណត់ចំណាត់ដី និងបង្កើតផែនទីដីបឋម ឈានទៅកសាងផែនការប្រើប្រាស់ដីកសិកម្ម សម្រាប់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅតំបន់គោលដៅ ១៣ ខេត្ត ។

៩.២- រៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកសិកម្ម របស់ក្រុមហ៊ុនវិនិយោគឯកជន ចំនួន ៩៥ ក្រុមហ៊ុន ក្នុងខេត្តចំនួន ១៧ ។

៩.៣- កំណត់តំបន់ប្រើប្រាស់ដីកសិកម្ម នៅខេត្តកំពង់ធំ សៀមរាប កំពង់ឆ្នាំង ពោធិសាត់បាត់ដំបង កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងឧត្តរមានជ័យ ។

<u>វិធានការគោលនយោបាយ៖</u>

*១០-រៀបចំកសាងច្បាប់ ស្តីពី ការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម សំដៅធ្វើឲ្យការប្រើប្រាស់ដីកសិកម្ម ប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។*

<u>សកម្មភាព៖</u>

១០.១- រៀបចំកសាងច្បាប់ ស្តីពី «ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម»។

១០.២- ពង្រឹងសមត្ថភាព និងបញ្ជ្រាបការប្រើប្រាស់ដី និងសម្ភារកសិកម្មសម្រាប់ដំណាំស្រូវ។

<u>វិធានការគោលនយោបាយ៖</u>

*១១-ធ្វើជំរឿនកសិកម្មជាតិ ក្នុងរយៈពេល ១០ ឆ្នាំម្តង។ ដោយផ្អែកលើលទ្ធផលជំរឿនកសិកម្មជាតិនេះ ត្រូវរៀបចំផែនទីដាំដុះ។*

<u>សកម្មភាព</u>៖

១១.១- រៀបចំធ្វើជំរឿនកសិកម្មជាតិ ដោយរួមសហការជាមួយ ក្រសួងផែនការ អង្គការ FAO និងដៃគូអភិវឌ្ឍន៍ដទៃទៀត ។

១១.២- រៀបចំកសាងផែនទីដាំដុះដំណាំទូទាំងប្រទេស ដោយត្រូវធ្វើសម្ភាសន៍ ប្រមូល កែច្នៃ និងវិភាគទិន្នន័យដែលប្រមូលបាន ក្នុងពេលធ្វើជំរឿនកសិកម្មជាតិ ហើយចងក្រងជារបាយការណ៍ និងផ្សព្វផ្សាយ។

<u>វិធានការគោលនយោបាយ (១២)</u>៖

*១២-ជំរុញការរៀបចំច្បាប់ ស្តីពី «សហគមន៍កសិកម្ម» និង អនុក្រឹត្យ ស្តីពី «ផលិតកម្មកសិកម្មតាមកិច្ចសន្យា»។*

<u>សកម្មភាព</u>៖

១២.១- រៀបចំកសាងច្បាប់ ស្តីពី «សហគមន៍កសិកម្ម»។

១២.២- រៀបចំគោលនយោបាយជាតិ សំរាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម។

១២.៣- សម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេស ដល់សហគមន៍ផលិតស្រូវ ចំនួន១៣០ ក្នុងភាពជាដៃគូ ជាមួយរោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ។

១២.៤- ជំរុញការពិភាក្សា និងអនុម័តលើ អនុក្រឹត្យ ស្តីពី «ផលិតកម្មកសិកម្មតាមកិច្ចសន្យា»។

## ១.២ វិធានការពាក់ពន្ធ័នឹងការប្រមូលទិញ និងការកែច្នៃស្រូវ

### ក. វិធានការបន្ទាន់

### ខ. វិធានការរយៈពេលមធ្យមនិងវែង

<u>វិធានការគោលនយោបាយ៖</u>

*១៣-កសាងនិងពង្រឹងសហគមន៍កសិកម្ម ឲ្យមានលទ្ធភាពអនុវត្តតាមទស្សនទាន «**ទីផ្សារស្រូវបើកចំហ**» តាមរយៈ សកម្មភាពមួយចំនួន ដូចជា ផលិតកម្មតាមកិច្ចសន្យា ជាមួយសមាជិកសហគមន៍កសិកម្ម ផ្តល់សេវាថ្លឹង ហាលស្រូវ បញ្ចាំស្រូវ ដើម្បីយកប្រាក់ទៅប្រើប្រាស់មុន ផ្តល់ពូជស្រូវមានមានគុណភាពខ្ពស់ និងជីគីមីជាដើម ដល់សមាជិកសហគមន៍កសិកម្ម ដើម្បីផលិតតាមតម្រូវការទីផ្សារ»*

<u>សកម្មភាព៖</u>

១៣.១- ផ្តល់វគ្គបណ្តុះបណ្តាលអំពីទស្សនទានទីផ្សារស្រូវបើកចំហ និងលិខិតបទដ្ឋាន ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា

១៣.២- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពគ្រប់គ្រងទីផ្សារស្រូវបើកចំហ និង កសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដល់សហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍គំរូចំនួន ៥

១៣.៣- បង្កើត និងដំណើរការទីផ្សារស្រូវបើកចំហ ដល់សហគមន៍កសិកម្មគំរូ ៥ កន្លែង។

## ១.៣ ឧបសគ្គការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករ

### ក. ឧបសគ្គការបន្ទាន់

<u>វិធានការគោលនយោបាយ (១៤)៖</u>

- *រៀបចំយុទ្ធសាស្ត្រអនុវត្តជាក់ស្តែងសម្រាប់អនុវត្ត ដោយកំណត់ច្បាស់ អំពីនីតិវិធីក្នុងដំណាក់កាលនីមួយៗ នៃការត្រួតពិនិត្យឯកសារនាំចេញ កម្រៃត្រូវបង់ និងពេលវេលា*
- *បែងចែកការទទួលខុសត្រូវ រវាងស្ថាប័នពាក់ព័ន្ធឲ្យបានច្បាស់លាស់ និងមានតម្លាភាពជាសាធារណៈ*
- *ចាត់ទុកការនាំចេញអង្ករជាអាទិភាព ពិសេសដោយចាត់វិធានការ កាត់បន្ថយការចំណាយក្រៅផ្លូវការ និងពេលវេលានាំចេញឲ្យបានជាអតិបរមា។*

<u>សកម្មភាព៖</u>

១៤.១- រៀបចំចងក្រងនិងផ្សព្វផ្សាយឯកសារ ស្តីពី «នីតិវិធីនៃការនាំចេញទំនិញ ជាកម្មវត្ថុការត្រួតពិនិត្យភូតគាមអនាម័យ» តាមរយៈសិក្ខាសាលាចំនួន ២ ដែលមានអ្នកចូលរួមចំនួន ៧០រូប និង បោះពុម្ព Leaflet ចំនួន 10.000 ច្បាប់

១៤.២- សិក្សាពីសមាសភាពចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាស-ភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រង និងផ្សព្វផ្សាយអត្ថបទបច្ចេកទេស ស្តីពី សមាសភាពចង្រៃលើអង្ករតាមរយៈ Poster ចំនួន ៥.០០០ ច្បាប់

១៤.៣- រៀបចំតំបន់គ្មានសមាសភាពចង្រៃ សំរាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិ ស្តីពី «វិធានភូតគាមអនាម័យ» ។

<u>វិធានការគោលនយោបាយ៖</u>

*១៥-រៀបចំ និង អនុវត្តយន្តការច្រកចេញចូលតែមួយ សម្រាប់ការបំពេញនីតិវិធីគយព្រមទាំងការចេញវិញ្ញាបនបត្រផ្សេងៗទៀត ដូចជាវិញ្ញាបនបត្រអនាម័យ និង វិញ្ញាបនបត្រ*

*ភូតគាមអនាម័យ (SPS) វិញ្ញាបនបត្រធូបទកម្ម (Fumigation) វិញ្ញាបនបត្របញ្ជាក់អំពីគុណភាព បរិមាណ និង ទម្ងន់ ។*

<u>សកម្មភាព</u>៖

១៥.១- ពង្រឹងសមត្ថភាពដោយបំពាក់សម្ភារបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធូបទ-កម្ម (Fumigation) លើផលិតផលស្តុក និងសម្ភារវេចខ្ចប់ពីឈើ ស្របតាមស្តង់ដារអន្តរជាតិឲ្យរួចរាល់ក្នុងឆ្នាំ ២០១១ ។

<u>វិធានការគោលនយោបាយ (១៦)</u>៖

- *កំណត់ស្តង់ដារគុណភាពអង្ករកម្ពុជាឲ្យស្របតាមស្តង់ដារអន្តរជាតិ*
- *ស្វែងរកសមត្ថភាពបច្ចេកទេស ដើម្បីសម្រេចបាននូវស្តង់ដារទាំងនោះ។*

<u>សកម្មភាព</u>៖

១៦.១- ជំរុញនិងសហការជាមួយវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំនិងកំណត់ស្តង់ដារអង្ករកម្ពុជា

១៦.២- រៀបចំផ្សព្វផ្សាយស្តង់ដារអង្ករកម្ពុជាដល់មន្ត្រីជំនាញកសិកម្ម សមាជិកសហគមន៍កសិកម្ម សមាគមម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនប្រមូលទិញ អ្នកនាំចេញ ដែលពាក់ពន្ធ័ក្នុងផលិតកម្ម អាជីវកម្ម នាំចេញអង្ករ

១៦.៣- រៀបចំសេចក្តីព្រាងច្បាប់ ស្តីពី គុណភាព និង សុវត្ថិភាពកសិផល

១៦.៤- បណ្តុះបណ្តាលគ្រូបង្គោល និងពង្រឹងសមត្ថភាពមន្ត្រីជំនាញ លើការគ្រប់គ្រងគុណភាព សុវត្ថិភាព ស្រូវ អង្ករ ដោយផ្អែកលើវិធាន GMP និង HACCP ។

## ខ. វិធានការរយៈពេលមធ្យមនិងវែង

<u>វិធានការគោលនយោបាយ (១៧)</u>៖

- *រៀបចំច្បាប់ស្តីពីភូតគាមអនាម័យ អនុក្រឹត្យ និងប្រកាសនានា ដែលពាក់ពន្ធ័*
- *ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឲ្យមានប្រសិទ្ធភាព*
- *កំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រអនាម័យ និងភូតគាមអនាម័យរួមមួយ ព្រមទាំងបែងចែកការទទួលខុសត្រូវរវាងស្ថាប័នពាក់ព័ន្ធឲ្យបានច្បាស់លាស់*
- *ពង្រឹងសមត្ថភាព និង ហេដ្ឋារចនាសម្ព័ន្ធត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។*

<u>សកម្មភាព៖</u>

១៧.១- រៀបចំសេចក្តីព្រាង និងដាក់ឆ្លងការពិភាក្សាតាមដំណាក់កាល នូវច្បាប់ ស្តីពី «ការការពាររុក្ខជាតិ និងភូតគាមអនាម័យ» ហើយនឹងត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ក្នុងឆ្នាំ ២០១៣

១៧.២- រៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «ការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម»

១៧.៣- រៀបចំសេចក្តីព្រាងប្រកាសស្តីពី នីតិវិធី និងការតម្រូវបមាណីយ សម្រាប់កិច្ចបញ្ជិកាថ្នាំកសិកម្ម និងសម្ភារកសិកម្ម

១៧.៤- រៀបចំប្រកាសចំនួន ៤ ដែលស្ថិតក្រោម អនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ដោយនឹងត្រូវអនុម័ត និងដាក់ឲ្យប្រើប្រាស់នៅដើមឆ្នាំ ២០១២ ដែលប្រកាសទាំង៤នេះ រួមមាន៖

- ✓ ប្រកាសស្តីពីសោហ៊ុយសេវាកម្ម ត្រួតពិនិត្យភូតគាមអនាម័យ និងកំចាត់សមាសភាពចង្រៃ
- ✓ ប្រកាសស្តីពីបញ្ជីរាយមុខទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
- ✓ ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌ សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ
- ✓ វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសំគាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ

១៧.៥- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍រោគវិនិច្ឆ័យរុក្ខជាតិ និងមន្ទីរពិសោធន៍វិភាគសំណល់ថ្នាំកសិកម្ម ក្នុងផលិតផលកសិកម្ម ដោយបំពាក់ឧបករណ៍ និងសម្ភារបច្ចេកទេសបន្ថែមទាំងនៅថ្នាក់កណ្តាល និងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ

១៧.៦- រៀបចំអនុក្រឹត្យ និងប្រកាស ស្ថិតនៅក្រោមច្បាប់ ស្តីពី ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

១៧.៧- រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងអត្ថបទក្រោមច្បាប់ ការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## ១.៤ ខធានការស្វែងរកទីផ្សារ

### ក. ខធានការបន្ទាន់

<u>វិធានការគោលនយោបាយ៖</u>

*១៨-បង្កើតស្ថាប័នព័ត៌មានទីផ្សារស្រូវ-អង្ករ សម្រាប់ប្រមូលចងក្រងព័ត៌មានស្រូវ-អង្ករ និងវិភាគស្ថានភាពទីផ្សារតំបន់និងពិភពលោក។*

សកម្មភាព៖

១៨.១- ធ្វើសិក្ខាសាលាបំពាក់បំប៉ន ដល់មន្ត្រីទីផ្សារនៅគ្រប់រាជធានីខេត្ត ស្តីពី វិធីសាស្ត្រការប្រមូលទិន្នន័យ ព័ត៌មានតម្លៃទីផ្សារកសិកម្ម តាមរយៈយន្តការដែលមានស្រាប់

១៨.២- ចុះទៅត្រួតពិនិត្យនិងតាមដាន ការប្រមូលទិន្នន័យព័ត៌មានតម្លៃកសិផល ដើម្បីធានាថា ព័ត៌មានដែលប្រមូលបាន មានលក្ខណៈត្រឹមត្រូវ

១៨.៣- ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវ-អង្ករ ក្នុងស្រុក សម្រាប់វិភាគអំពីស្ថានភាពទីផ្សារក្នុងប្រទេស

១៨.៤- ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និង ចរាចរស្រូវ-អង្ករ ក្នុងប្រទេស និង តាមបណ្តាខេត្តជាប់ព្រំដែន និង រៀបចំធ្វើបញ្ជីអ្នកនាំចេញអង្ករ

១៨.៥- ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវ-អង្ករ ក្នុងតំបន់ និងអន្តរជាតិ សម្រាប់វិភាគអំពីស្ថានការទីផ្សារតំបន់ និង អន្តរជាតិ

វិធានការគោលនយោបាយ៖

*១៩-បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារ និងប្រែក្លាយព័ត៌មានទាំងនោះ ឲ្យជាសកម្មភាពជាក់ស្តែង ទាំងក្នុងផលិតកម្ម ការកែច្នៃ ការនាំចេញ និងពាណិជ្ជកម្ម។*

សកម្មភាព៖

១៩.១- ផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុក ក្នុងតំបន់ និងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ និង គេហទំព័រ។

## ខ. ទិធានការរយៈពេលមធ្យមនិងវែង

វិធានការគោលនយោបាយ (២០)៖

- *កំណត់គោលដៅយុទ្ធសាស្ត្រឲ្យបានច្បាស់លាស់ ដើម្បីឈរជើងលើទីផ្សារអន្តរជាតិ*
- *បន្តធ្វើសកម្មភាពស្វែងរកទីផ្សារ និងចរចាកិច្ចព្រមព្រៀងលក់*
- *ផ្សព្វផ្សាយព័ត៌មានទីផ្សារជូនដល់ផលិតករ និងអ្នកនាំចេញ*
- *កសាងសមត្ថភាពមន្ត្រីក្នុងការស្វែងរកទីផ្សារ*

សកម្មភាព៖

២០.១- ភ្ជាប់គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ជាមួយនឹងគេហទំព័រទីផ្សារអង្ករអន្តរជាតិ ដើម្បីផ្សាយព័ត៌មានទីផ្សារជូនដល់ផលិតករ អ្នកប្រមូលទិញ និងអ្នកនាំចេញ។

## II- គម្រោងថវិកា សម្រាប់អនុវត្តសកម្មភាព

ដើម្បីអនុវត្តផែនការសកម្មភាព សម្រាប់គាំទ្រឯកសារគោលនយោបាយ ស្តីពី «ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ» ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការថវិកាសរុបចំនួន ១៩២.១០២ លានរៀល (៤៨.០២៥.០០០ ដុល្លារអាមេរិក) សម្រាប់អនុវត្តរយៈពេល៥ឆ្នាំ (២០១១-២០១៥) ដែលក្នុងនោះ ថវិកាចំនួន ២១.៩២២ លានរៀល គ្រោងសម្រាប់អនុវត្តបណ្តាសកម្មភាពគាំទ្រដល់វិធានការបន្ទាន់និងផ្តល់ផលភ្លាមៗ និង ថវិកាចំនួន ១៧០.១៨០ លានរៀល គ្រោងសម្រាប់រយៈពេលមធ្យម និងវែង។

បណ្តាអង្គភាពជំនាញ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ពន្ធ័នឹងការអនុវត្តផែនការសកម្មភាពនេះ ត្រូវរៀបចំផែនការថវិកាលំអិត ដើម្បីដាក់បញ្ចូលទៅក្នុងក្របខណ្ឌថវិកាតាមកម្មវិធី ចំពោះសកម្មភាពដែលមានចរិតជាចំណាយចរន្ត និង ត្រូវត្រៀមរៀបចំនិងដាក់បញ្ចូលនូវបណ្តាសកម្មភាព (ឬគម្រោងលំអិត) ដែលជាចំណាយមូលធន ទៅក្នុងកម្មវិធីវិនិយោគសាធារណៈ ដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា។

អង្គភាពរៀបចំផែនការថវិកា និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពសំខាន់មកពី នាយកដ្ឋាន ផែនការនិងស្ថិតិ និង នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ត្រូវរៀបចំចាត់ចែង និងសម្របសម្រួល ក្នុងការងាររៀបចំផែនការសកម្មភាព និងថវិកា សំដៅធ្វើយ៉ាងណាឲ្យសកម្មភាពទាំងឡាយក្នុងផែនការនេះ អាចអនុវត្តបានដោយមានប្រសិទ្ធភាពខ្ពស់។

## III- យន្តការអនុវត្ត - ការតាមដាន និងវាយតម្លៃ

### ១. យន្តការអនុវត្ត

- អគ្គនាយកដ្ឋានកសិកម្ម: គឺជាអង្គភាពជំនាញដែលសំខាន់បំផុត ក្នុងការអនុវត្តផែនការសកម្មភាពនេះ។ សកម្មភាពជាច្រើននឹងត្រូវអនុវត្តដោយអង្គភាពនេះ ពិសេសការងារដែលពាក់ពន្ធ័នឹងការបង្កើនផលិតភាពដំណាំស្រូវ និងការសម្រួលពាណិជ្ជកម្ម តាមរយៈ ការពង្រឹងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងផលិតកម្ម ពិសេស ការផ្ទេរបច្ចេកវិទ្យាកសិកម្ម ការប្រមូលផ្តុំផលិតកម្ម (សហគមន៍កសិកម្ម) ការគ្រប់គ្រងដីកសិកម្ម ការអនុវត្តច្បាប់ពូជដំណាំ ការងារអនាម័យនិងភូតគាមអនាម័យ ការគ្រប់គ្រងហានិភ័យ ។ល។ ការងារលំអិតមានចែងច្បាស់ក្នុងផែនការសកម្មភាព ដើម្បីអនុវត្តឯកសារគោលនយោបាយ ស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។
- វិទ្យាស្ថាន ស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា: អង្គភាពជំនាញនេះ នឹងត្រូវអនុវត្តនូវសកម្មភាពនានា ដែលពាក់ពន្ធ័នឹង *«ការអភិវឌ្ឍពូជស្រូវ»* សមស្របនឹងប្រព័ន្ធអេកូឡូស៊ីបរិស្ថាន និងតម្រូវការទីផ្សារត្រូវការ។ ពូជស្រូវដែលបានកំណត់សម្រាប់ជំរុញការធ្វើ

ផលិតកម្មដំណាំស្រូវឱ្យកាន់តែទទួលបាននូវទិន្នផលខ្ពស់រួមមានៈ **ពូជស្រូវស្រាលមិនប្រកាន់រដូវ**ចំនួន ៣ ពូជ គឺពូជ សែនពិដោរ ពូជជលសារ និងពូជ IR66 **ពូជស្រូវកណ្តាល**ចំនួន ៤ ពូជ គឺពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាចន្ទ័សែនសរ **ពូជស្រូវធ្ងន់**ចំនួន ៣ ពូជ គឺពូជរាំងជ័យ ពូជខា ៤ និង ពូជខា ៦ ។ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នឹងត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចការនេះ ហើយត្រូវអនុវត្តនូវបណ្តាសកម្មភាពនានា ដូចមានលំអិតក្នុងផែនការសកម្មភាពនេះ។

- ***បណ្តានាយកដ្ឋានជំនាញនានា ដែលផ្តល់សេវាគាំទ្រៈ*** អង្គភាពជំនាញនានាផ្សេងទៀត ដូចជា នាយកដ្ឋាននីតិកម្មកសិកម្ម នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានកសិ-ឧស្សាហកម្ម ក៏ត្រូវអនុវត្តសកម្មភាពរបស់ខ្លួនដូចមានលំអិតក្នុងផែនការសកម្មភាពនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់។
- ***បណ្តាមន្ទីរកសិកម្ម រាជធានី ខេត្តៈ*** សកម្មភាពជាច្រើននឹងត្រូវបានអនុវត្តនៅមូលដ្ឋាន ហើយតម្រូវឱ្យមន្ទីរកសិកម្មរាជធានី ខេត្ត និងអង្គភាពជំនាញ ត្រូវរួមសហការគ្នាអនុវត្តនូវផែនការសកម្មភាពនេះ ឱ្យទទួលបានជោគជ័យតាមការគ្រោងទុក។

### ២. ការតាមដាននិងវាយតម្លៃ

- ***នាយកដ្ឋានផែនការនិងស្ថិតិ*** មានភារកិច្ច ពិនិត្យតាមដាន និង វាយតម្លៃ លើការអនុវត្តរាល់សកម្មភាពនានា ដូចមានចែងក្នុងផែនការសកម្មភាពនេះ។
- បណ្តានាយកដ្ឋាន អង្គភាពជំនាញនានា ដែលពាក់ពន្ធ័ក្នុងការអនុវត្តផែនការសកម្មភាពនេះ ត្រូវរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបាន ឲ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍ប្រចាំឆមាស ៩ខែ និង ប្រចាំឆ្នាំ។
- របាយការណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ នឹងត្រូវរៀបចំដោយនាយកដ្ឋានផែនការនិងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួង ពិនិត្យនិងសម្រេច នៅរៀងរាល់បំណាច់ឆ្នាំនីមួយៗ ។
- ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងត្រូវធ្វើការបូកសរុប រួចរាយការណ៍ជូនទៅ គណៈកម្មាធិការជំរុញការនាំចេញកសិផល ដើម្បីមានជាមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

## IV- ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យ ត្រូវបានបង្ហាញក្នុងឯកសារគោលនយោបាយ ស្តីពី ការជំរុញ ផលិត-កម្មស្រូវ និងការនាំចេញអង្ករ ដែលមានខ្លឹមសារដូចខាងក្រោមៈ

- **កត្តាអាកាសធាតុ:** ផលិតកម្មដំណាំស្រូវ ពឹងផ្អែកលើកត្តាធម្មជាតិច្រើន ពិសេស ការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យមានគ្រោះទឹកជំនន់ រាំងស្ងួត សត្វល្អិតបំផ្លាញ ។ល។ ហើយនឹងធ្វើឲ្យខូចខាតដល់ផលិតកម្មដំណាំស្រូវ ។
- **កំណើនថ្លៃប្រេង:** កំណើនថ្លៃប្រេងខ្ពស់ នឹងជះឥទ្ធិពលដល់ផលិតកម្ម ការកែច្នៃ និង ការដឹកជញ្ជូន ដែលនាំឲ្យសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាអាចធ្លាក់ចុះ។
- **ភាពមិនច្បាស់លាស់នៃទីផ្សារ:** ទីផ្សារអង្ករ ជាទីផ្សារមានការគាំពារខ្ពស់ ។ ការប្រែប្រួលខាងនយោបាយរបស់ប្រទេសនាំចូល នឹងអាចជះឥទ្ធិពលចំពោះ បរិមាណតម្រូវការ និងតម្លៃនាំចេញ។
- **សន្តិសុខស្បៀង:** ការបើកចំហចំពោះការនាំចេញទាំងស្រូវនិងអង្ករ អាចធ្វើឲ្យអង្ករឡើងថ្លៃ ហើយយន្តការប្រមូលទិញក្នុងស្រុកមិនទាន់រឹងមាំ អាចបណ្តាលឲ្យមានបញ្ហាសន្តិសុខស្បៀងក្នុងប្រទេស ។
- **បរាជយ័ក្នុងការបែងចែក:** ផលចំណេញពីវិធានការគោលនយោបាយនេះ អាចនឹងមិនបែងចែកប្រយោជន៍ផ្ទាល់ដល់កសិករ ពោលគឺអាចបានទៅលើឈ្មួញកណ្តាល ឬអ្នកកែច្នៃ ។ល។ ការបែងចែកផលប្រយោជន៍ ការប្រកាន់គោលការណ៍ទីផ្សារសេរី ការប្រកួតប្រជែងសុច្ចរិត ការធានាឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ គឺជាចំណុចគន្លឹះដែលនឹងត្រូវប្រតិបត្តិ។
- **ការប៉ះពាល់ប្រពន្ធ័អេកូឡូស៊ី:** អាចនឹងមានការប្រើប្រាស់ជីគីមី ថ្នាំកសិកម្ម ក្នុងកំរិតខ្ពស់ក្នុងតំបន់ផលិតកម្មមួយចំនួន និង ការរុករានដីព្រៃ-ព្រៃលិចទឹក ដើម្បីពង្រីកផ្ទៃដីដាំដុះ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី។
- **ភាពស្មុគ្រស្មាញនៃការអនុវត្ត:** ក្នុងការអនុវត្តជាក់ស្តែង នឹងអាចមានការលំបាក និង ភាពស្មុគ្រស្មាញខ្លះ ដោយសារការសម្របសម្រួលមិនមានប្រសិទ្ធភាព និងការទទួលខុសត្រូវមិនច្បាស់លាស់ ក្នុងចំណោមអង្គភាព ស្ថាប័នជំនាញដែលត្រូវអនុវត្ត។ល។

## V- សេចក្តីសន្និដ្ឋាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្តេជ្ញាចិត្តខ្ពស់ ក្នុងការជំរុញការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា និង បង្កើនល្បឿននៃការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ដោយសារកម្ពុជាមានសក្តានុពលផ្នែកផលិតកម្មកសិកម្ម ពិសេស វិស័យស្រូវ-អង្ករ គោលនយោបាយសម្រាប់ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ពិតជាមានសារសំខាន់បំផុត ក្នុងការជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយ សម្រាប់ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលបានរៀបចំកសាងឡើងនេះ នឹងអាចអនុវត្តបានជោគជ័យ គឺអាស្រ័យដោយការតាំងចិត្តពុះពារ រួមនឹងការជួយឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី និងសម្ភារ ថវិកា ពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា មានការចូលរួមចំណែកពីបណ្តាដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តនូវបណ្តា

សកម្មភាព និងវិធានការគោលនយោបាយទាំងឡាយ ដូចដែលបានរៀបរាប់ ក្នុងឯកសារគោលនយោបាយនេះ។

កត្តាអវិជ្ជមាន និងឧបសគ្គនានាដែលនឹងអាចរាំងស្ទះ ក្នុងការជំរុញផលិតកម្មដំណាំស្រូវ គឺកត្តាគ្រោះថ្នាក់ពីធម្មជាតិដែលនឹងអាចកើតមាន ដូចជា គ្រោះទឹកជំនន់ ភាពរាំងស្ងួត កត្តាបំផ្លិចបំផ្លាញពីសត្វល្អិតចង្រៃ ។ល។ ប៉ុន្តែទោះជាយ៉ាងណាក្តី ឧបសគ្គទាំងនេះនឹងអាចកាត់បន្ថយបាន តាមរយៈការតាំងចិត្ត និងការខិតខំជំនះ ដើម្បីទទួលបានជោគជ័យ ក្នុងការអភិវឌ្ឍវិស័យស្រូវ-អង្ករនេះ។

ម្យ៉ាងវិញទៀត ជោគជ័យអាចនឹងទទួលបានពេញលេញ នៅពេលដែលមានការចូលរួមពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធក្នុងវិស័យផលិតកម្មស្រូវនិងការនាំចេញអង្ករ ដោយត្រូវរួមគ្នាដោះស្រាយបញ្ហាប្រឈម ជាពិសេស ត្រូវធ្វើយ៉ាងណាឱ្យដំណើរការនាំចេញអង្ករ មានភាពរលូន មិនស្មុគ្រស្មាញច្រើន កាត់បន្ថយពេលវេលា និងចំណាយក្រៅផ្លូវការ ក៏ដូចជាការកាត់បន្ថយថ្លៃដើមផលិតកម្ម កែច្នៃ និងនាំចេញ ដែលនឹងធ្វើឱ្យអង្ករកម្ពុជា អាចប្រកួតប្រជែងលើទីផ្សារអន្តរជាតិបាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
********

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការ និងស្ថិតិ
********

# ផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយ ស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

| ប្រភេទនៃវិធានការ | បញ្ហាត្រូវដោះស្រាយ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ឆ្នាំ | | លទ្ធផលរំពឹងទុក | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|
| | | | | ២០១០-២០១១ លានរៀល | ២០១១-២០១៥ លានរៀល | | |
| **ពាក់ព័ន្ធនឹងផលិតកម្មស្រូវ** | | | | | | | |
| វិធានការបន្ទាន់ និងផ្តល់ផលភ្លាមៗ | បង្កើនផលិតភាពក្នុងការផលិតស្រូវ ដោយប្រើប្រាស់ពូជមានទិន្នផលខ្ពស់ និងធ្វើស្រែតាមក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវ | -សម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្ម និងគ្រឿងយន្តកសិកម្ម | -រៀបចំកែលម្អនីតិវិធីជួយសម្របសម្រួលការធ្វើអាជីវកម្ម ការចុះបញ្ជិកា និងការនាំចូលសម្ភារកសិកម្ម | ៣០ | | ព័ត៌មានបង្ហាញផ្លូវសម្រាប់អតិថិជន ស្តីពីការកែសម្រួលនីតិវិធីក្នុងការធ្វើអាជីវកម្ម ការចុះបញ្ជិកា និងការនាំចូលសម្ភារកសិកម្ម ត្រូវបានកំណត់ច្បាស់លាស់ និងដាក់ឲ្យប្រើប្រាស់ | ន.ន.ក<br>អ.ន.ក |
| | | -បន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធលើការនាំចូលចំពោះសម្ភារ និងបរិក្ខារទាំងនោះ | -រៀបចំបញ្ជីឈ្មោះគ្រឿងយន្តកសិកម្ម ដើម្បីសម្របសម្រួលការនាំចូល | ៤០ | | បញ្ជីឈ្មោះគ្រឿងយន្តកសិកម្ម សមស្រប នឹងត្រូវបានរៀបចំ | អ.ន.ក |
| | | -ផ្តល់ការលើកទឹកចិត្តដល់ផលិតករនឹងការបែងចែកពូជក្នុងស្រុក<br><br>១-កំណត់ប្រភេទពូជស្រូវសំខាន់ៗមួយចំនួនដែលជាគោលដៅអាទិភាពជំរុញផលិតកម្ម និងការផ្សព្វផ្សាយប្រើប្រាស់ពូជឲ្យបានស្រេចបាច់នៅមុនដំណាច់ឆ្នាំ២០១០ នេះនិងរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការដើម្បីលើកស្ទួយដល់ផលិតកម្ម និងការបែងចែកផ្សព្វផ្សាយប្រើប្រាស់ពូជឲ្យ | ១.១-កំណត់ប្រភេទពូជស្រូវសំខាន់ៗមួយចំនួនដែលសមស្របសម្រាប់ប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ មានសក្តានុពលទិន្នផលខ្ពស់ និងមានគុណភាពស្របតាមតម្រូវការទីផ្សារជាតិ និងអន្តរជាតិ (បានអនុវត្តរួចហើយ) | - | - | ពូជស្រូវយ៉ាងតិចបំផុតចំនួន១០ពូជត្រូវបានកំណត់ជាបឋមដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) | កាឌី |
| | | | ១.២- សិក្ខាសាលាពិគ្រោះយោបល់លើប្រភេទពូជស្រូវមួយចំនួនជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធ (បានអនុវត្តរួចហើយ) | ៨ | | ពូជស្រូវសំខាន់ៗចំនួន ១០ ដែលបានកំណត់ដោយក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ត្រូវបានឯកភាពទទួលយកពីអ្នកពាក់ពន្ធ័ | កាឌី |
| | | | ១.៣- រៀបចំសារាចរណែនាំឱ្យប្រើប្រាស់ពូជស្រូវដែលបានកំណត់រួច និងផ្សព្វផ្សាយ | ៣០ | | សារាចរណែនាំអំពីពូជស្រូវបានត្រូវដាក់ចេញ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | បានស្រេចបាច់នៅមុនបំណាច់ឆ្នាំ២០១០ នេះដែរ ។ | ១.៤-ចងក្រង និងបោះពុម្ពសៀវភៅស្តីអំពីលក្ខណៈពូជស្រូវដែលបានកំណត់ រួមទាំងវិធីសាស្ត្រសម្រិតសម្រាំងពូជស្រូវតាមបែបកសិករ ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ជី និងលក្ខខណ្ឌក្សេត្របរិស្ថានដំណាំស្រូវ និងចែកចាយជូនអង្គភាពជំនាញរបស់ក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក ក្រុមប្រឹក្សាឃុំ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ (ថវិកាបន្ថែម) | ១០០ | | សៀវភៅចំនួនសរុប ១០.០០០ច្បាប់ត្រូវបានចងក្រង បោះពុម្ព និងចែកចាយជូនអង្គភាពឬផ្នែកពាក់ព័ន្ធ | កាឌី |
| | | | ១.៥-ចងក្រង និងបោះពុម្ពផ្សព្វផ្សាយសៀវភៅបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ (Technology Package for Increased RiceProductivity=TPIRP) សម្រាប់ប្រភេទ ឬក្រុមនៃពូជស្រូវ ដែលបានកំណត់ឲ្យប្រើប្រាស់ និងចែកជូនអង្គភាពជំនាញរបស់ កសក មន្ទីរកសិកម្មរាជធានី-ខេត្ត ការិយាល័យកសិកម្ម ស្រុក ក្រុមប្រឹក្សាឃុំ ក្រុមហ៊ុនឯកជន និង អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ (ថវិកាបន្ថែម) | ១០០ | | សៀវភៅបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវចំនួនសរុប ៥.០០០ ច្បាប់ត្រូវបានបោះពុម្ព និងចែកចាយជូនអង្គភាពជំនាញនិងអ្នកពាក់ព័ន្ធ | កាឌី |
| | | | ១.៦- បើកវគ្គបណ្តុះបណ្តាលគ្រូជំនាញ (Master trainers) ចំនួន ០២ វគ្គ (១)លក្ខណៈសំខាន់ៗ របស់ពូជស្រូវទាំង១០ (២) វិធីសាស្ត្រសម្រិតសម្រាំងពូជស្រូវតាមបែបកសិករ (៣)ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ជី (៤)លក្ខខណ្ឌក្សេត្របរិស្ថានដំណាំស្រូវ និង (៥)បង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ ដើម្បីឲ្យមន្ត្រីទាំងនោះក្លាយជាគ្រូជំនាញ សម្រាប់បណ្តុះបណ្តាលគ្រូបង្គោលបន្តទៀត (ថវិកាបន្ថែម) | ៥០ | | មន្ត្រីជំនាញកសិកម្ម នៃនាយកដ្ឋានដំណាំស្រូវ មន្ទីរកសិកម្មរាជធានី ខេត្ត ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធចំនួន ៣០នាក់នឹងក្លាយជាគ្រូជំនាញ | កាឌី |
| | | | ១.៧- រៀបចំកែសម្រួល និងបោះពុម្ពឯកសារស្តីពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវរបស់ CARDI ឲ្យស្របតាមសមត្ថភាពរបស់គ្រូបង្គោល | ៥០ | | ឯកសារកែសម្រួលសម្រាប់គ្រូបង្គោលអំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវចំនួន ៥.០០០ ច្បាប់ ត្រូវបានបោះពុម្ព និងបែងចែក | អ.ន.ក |
| | | | ១.៨-បណ្តុះបណ្តាលគ្រូបង្គោលតាមខេត្ត អំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ រួមទាំងបច្ចេកទេសការពារដំណាំស្រូវ សមាសភាពចង្រៃ និងវិធានការកំចាត់ | ៦០០ | | គ្រូបង្គោលចំនួន ១.៥០០ នាក់ នៅ ១០ ខេត្ត ត្រូវបានបណ្តុះបណ្តាល | អ.ន.ក |
| | | | ១.៩-បើកវគ្គបណ្តុះបណ្តាលកសិករតាមខេត្ត ស្តីពីបង្កុំ | ៦០០ | | កសិករចំនួន ២៥.០០០ នាក់នៅខេត្ត | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | បច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ សមាសភាពចង្រៃ និងវិធានការកំចាត់ | | | ចំនួន ១០ ត្រូវបានបណ្តុះបណ្តាល | |
| | | | ១.១០- ធ្វើស្រែបង្ហាញអំពីបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវតាមតំបន់ស្រោចស្រព | ២.១៦០ | | ស្រែបង្ហាញចំនួន ៥០០ កន្លែងត្រូវបានអនុវត្តនៅតាមខេត្ត | អ.ន.ក |
| | | | ១.១១- ផលិតគ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវដែលបានកំណត់ចំនួន ៥ ហិកតាតាមរយៈគម្រោង CBAPP និង ២ ហិកតាតាមរយៈថវិការដ្ឋាភិបាល ២០១១ សម្រាប់ចែកចាយជូនកសិករគម្រោង CBAPP និងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់ក្នុងឆ្នាំ ២០១១ និង ២០១២ | ១៥០ | | គ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវដែលបានកំណត់ចំនួន ១០.៥០០ គ.ក្រ ត្រូវបានផលិត និងប្រើប្រាស់ | កាឌី |
| | | | ១.១២- ផលិតគ្រាប់ពូជសុទ្ធទទួលស្គាល់របស់ពូជស្រូវដែលបានកំណត់លើផ្ទៃដីចំនួន ៥ ហិកតាសម្រាប់ចែកចាយនិងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់ក្នុងឆ្នាំ ២០១១ និង ២០១២ (ថវិកាបន្ថែម) | ១០០ | | គ្រាប់ពូជសុទ្ធទទួលស្គាល់របស់ពូជស្រូវដែលបានកំណត់ចំនួន ៨.៥០០ គ.ក្រ ត្រូវបានផលិត និងចែកចាយ | កាឌី |
| | | | ១.១៣- ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាត នៅតាមស្ថានីយ៍លើកដំបូងលើផ្ទៃដី ៥០ ហិកតា | ៥០០ | | គ្រាប់ពូជអនុញ្ញាតទទួលស្គាល់ចំនួន ១៥០ តោន ត្រូវបានផលិត និងផ្គត់ផ្គង់ជូនកសិករប្រើប្រាស់ | អ.ន.ក |
| | | | ១.១៤-ផលិតគ្រាប់ពូជសុទ្ធល្អនៅតាមស្ថានីយ៍និងសហគមន៍កសិករ លើផ្ទៃដី៤៥០ហិកតា (គំរោង ADB Emergency Food Assistance បានសំរេចផ្តល់រួចហើយ) | ២.២៦៨ | | គ្រាប់ពូជសុទ្ធល្អចំនួន ១.៣៥០តោនត្រូវបានផលិតនិងផ្គត់ផ្គង់ជូនកសិករក្នុងតំបន់គោលដៅ | អ.ន.ក |
| | | | ១.១៥-បោះពុម្ពឯកសារបច្ចេកទេសស្តីពីផលិតកម្មគ្រាប់ពូជសុទ្ធល្អ និងផ្សព្វផ្សាយ | ១០០ | | ឯកសារ ១០.០០០ ច្បាប់ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយឱ្យប្រើប្រាស់ | អ.ន.ក |
| | | | ១.១៦- បណ្តុះបណ្តាលសហគមន៍កសិករ ស្តីពី បច្ចេកទេសផលិតកម្មគ្រាប់ពូជសុទ្ធល្អ | ១៦០ | | កសិករ ១៦០០ នាក់ នៅ ២០សហគមន៍ត្រូវបានបណ្តុះបណ្តាល | អ.ន.ក |
| | | | ១.១៧-រៀបចំគោលការណ៍ យន្តការ និងឯកសារវាយតម្លៃ និងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ | ៣០ | | ឯកសារវាយតម្លៃនិងបញ្ជាក់គុណភាពគ្រាប់ពូជសុទ្ធត្រូវរៀបចំនិងដាក់ឱ្យប្រើប្រាស់ | អ.ន.ក |
| | | | ១.១៨ -គ្រោងស្តុក និងផ្តល់ឥណទានស្រូវពូជមានគុណភាពខ្ពស់ប្រចាំឆ្នាំសម្រាប់ត្រៀមការស្តារការខូចខាតដោយគ្រោះធម្មជាតិទឹកជំនន់ និងគ្រោះរាំងស្ងួតតាមបណ្តារាជធានី-ខេត្ត | ១.៥០០ | | ស្រូវពូជចំនួន ១.០០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារត្រូវបានផ្តល់ជូនកសិករខ្ចីប្រើប្រាស់រៀងរាល់ឆ្នាំសម្រាប់ស្តារការខូចខាត ដោយគ្រោះធម្មជាតិ | ន.ផ.ស |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ១.១៩-ស្រូវពូជត្រៀមអន្តរាគមន៍សង្គ្រោះបន្ទាន់ ប្រចាំឆ្នាំ សម្រាប់ការស្តារការខូចខាតដោយគ្រោះធម្មជាតិ ទឹកជំនន់ និងគ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត | ១.៣០០ | | ស្រូវពូជចំនួន ៥០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារត្រូវបានចែកជូនកសិករប្រើប្រាស់រៀងរាល់ឆ្នាំដើម្បីស្តារការខូចខាតដោយគ្រោះធម្មជាតិ | ន.ផ.ស |
| | | ២-ពង្រឹង និងពង្រីកសមត្ថភាព វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម កសិដ្ឋានសម្រាប់ផលិតពូជ សិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលបច្ចេកទេស | ២.១- សិក្សា និងរៀបចំផែនការលំអិតដើម្បីពង្រឹងនិងពង្រីក កសិដ្ឋាន ស្ថានីយ៍ និងមណ្ឌលអភិវឌ្ឍន៍សំរាប់ផលិតកម្មពូជស្រូវ | ១០០ | | ផែនការសកម្មភាពនិងការចំណាយលំអិតនៅស្ថានីយ៍ ០៧ ត្រូវបានសិក្សានិងរៀបចំ | អ.ន.ក |
| | | | ២.២-ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាជំហានដំបូងនៅកសិដ្ឋានផលិតពូជស្រូវទួលសំរោងដើម្បីគាំទ្រដល់ការផលិតពូជ (គំរោង ADB Emergency Food Assistance បានសំរេចផ្តល់រួចហើយ) | ២៧៣ | | ប្រព័ន្ធប្រឡាយបញ្ចូល–បញ្ចេញទឹក និងឃ្លាំងរក្សាគ្រាប់ពូជត្រូវបានជួសជុល និងឡសម្ងួតគ្រាប់ពូជត្រូវបានសាងសង់ | អ.ន.ក |
| | | | ២.៣ - រៀបចំកែលំអឯកសារ និងផែនការ ពិសោធន៍ស្រាវជ្រាវបន្សាំតាមប្រភេទ ប្រពន្ធ័អេកូឡូស៊ីផ្សេងៗ | ៧០ | | ឯកសារ និងផែនការពិសោធន៍ស្រាវជ្រាវបន្សាំតាមប្រភេទប្រពន្ធ័អេកូឡូស៊ីផ្សេងៗ ត្រូវបានរៀបចំជាថ្មី | អ.ន.ក |
| | | | ២.៤-កំណត់តំបន់ផលិតកម្មស្រូវ ដែលមានប្រភពទឹក និងប្រពន្ធ័ធារាសាស្រ្ត | ១៥០ | | តំបន់គោលដៅផលិតកម្មស្រូវ ដែលមានប្រភពទឹក ត្រូវបានកំណត់ | អ.ន.ក |
| | | | ២.៥-រៀបចំចងក្រង និងបោះពុម្ពផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសមាសភាពចង្រៃ (សត្វល្អិតចង្រៃ ជំងឺ និងស្មៅចង្រៃ) លើដំណាំស្រូវ និងថ្នាំកសិកម្ម និងការប្រើប្រាស់ | ៥០០ | | Poster & Leaflet ចំនួន ១០.០០០ ច្បាប់ ត្រូវបានចែកជូនដល់កសិករដែលដាំដុះដំណាំស្រូវ | អ.ន.ក |
| | | | ២.៦- កំណត់តំបន់គ្មានសមាសភាពចង្រៃលើដំណាំស្រូវ ដើម្បីសម្របសម្រួលការធ្វើពាណិជ្ជកម្មអង្ករ ទៅកាន់ទីផ្សារអន្តរជាតិ | ១២០ | | តំបន់គោលដៅ គ្មានសមាសភាពចង្រៃ ចំនួន២តំបន់នឹងត្រូវបានកំណត់ | អ.ន.ក |
| | | | ២.៧- សិក្សាពីប្រភេទសមាសភាពចង្រៃ លើដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា, រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ, រៀបចំចងក្រង និងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសត្វល្អិតចង្រៃលើដំណាំស្រូវ | ១.០០០ | | បញ្ជីឈ្មោះ និងសំណាកសមាសភាពចង្រៃលើដំណាំស្រូវត្រូវបានរៀបចំ និងរក្សាទុក និង Poster ចំនួន ៥.០០០ ច្បាប់ ត្រូវបានបោះពុម្ពផ្សព្វផ្សាយ | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ២.៨-ត្រៀមថ្នាំកសិកម្មនិងឧបករណ៍សម្រាប់អន្តរាគមន៍បន្ទាន់ក្នុងការកំចាត់សមាសភាពចង្រៃនៅពេលមានការផ្ទុះឡើងការបំផ្លាញដើម្បីធានាថាគ្មានការបាត់បង់ទិន្នផលបើទោះបីមានការបំផ្លាញក៏ដោយ | ១.០០០ | | –ថ្នាំកសិកម្មចំនួន ២៨.០០០លីត្រ និងម៉ាស៊ីនបាញ់ចំនួន១០០គ្រឿង ត្រូវបានត្រៀមជាស្រេចសំរាប់អន្តរាគមន៍លើផ្ទៃដីប្រមាណ ១៤.០០០ ហិកតា (០.៥% នៃផ្ទៃដីសរុប) ត្រូវបានអន្តរាគមន៍ | អ.ន.ក |
| | | | ២.៩- បំពាក់ឧបករណ៍កសិកម្មតាមរយៈគម្រោង Community Based Agricultural Productivity Project (CBAPP) នូវត្រាក់ទ័រចំនួន ០១ គ្រឿង និង mini-combined harvester ចំនួន ០១ គ្រឿង និងគម្រោងស្រោចស្រព និងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនូវត្រាក់ទ័រចំនួន ០៣ គ្រឿង និងគ្រឿងបរិក្ខាភ្ជួររាស់ចំនួន ០៣ សម្រាប់ រួមទាំងម៉ាស៊ីនបោកស្រូវចំនួន ០១ គ្រឿង និងម៉ាស៊ីនបូមទឹកដើរដោយថាមពលអគ្គិសនី ពាង និងបណ្តាញខ្សែភ្លើងត្រូវបានបំពាក់នៅស្រះទឹកចំនួន ០៤ នៅក្នុងវិទ្យាស្ថាន | ៩៥២ | | ការរៀបចំដី និងគ្រប់គ្រងទឹកសម្រាប់ពិសោធន៍ និងផលិតកម្មគ្រាប់ពូជដំណាំបានទាន់ពេលវេលា ជាមួយការកាត់បន្ថយថវិកាជួសជុល ថែទាំ និងប្រេងឥន្ធនៈ | កាឌី |
| | | | ២.១០- បំពាក់ឧបករណ៍មន្ទីរពិសោធន៍គ្រាប់ពូជ និងបណ្តុះបណ្តាលឲ្យចេះប្រើប្រាស់ តាមរយៈគម្រោង CBAPP | ៥២០ | | មន្ទីរពិសោធន៍គ្រាប់ពូជត្រូវបានបំពាក់ឧបករណ៍សម្រាប់ធ្វើការវិភាគគុណភាពគ្រាប់ពូជ និងមន្ត្រី និយោជិក មានសមត្ថភាពវិភាគបានត្រឹមត្រូវ | កាឌី |
| | | | ២.១១- ថង់ប្លាស្ទីក Volcanic cube (cocune ) សំរាប់ចំណុះ ៣ តោនចំនួន ១០ សំរាប់ចំណុះ ៥ តោន ចំនួន ៣ និងសំរាប់ចំណុះ ១០ តោន ចំនួន ២ សម្រាប់ទុកគ្រាប់ពូជស្រូវ (ថវិកាបន្ថែម) | ១០០ | | គ្រាប់ពូជស្រូវត្រូវបានទុកប្រកបដោយគុណភាព និងសុវត្ថភាព | កាឌី |
| | | ៣-ពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម (Extension Services) | ៣.១-សិក្សា វាយតម្លៃស្ថានភាពបច្ចុប្បន្នលើប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្ម | ១.០០០ | | ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម នៅតាមបណ្តាខេត្តទាំង ១០ នឹងត្រូវបានធ្វើការវាយតម្លៃ។ របាយការណ៍វាយតម្លៃមួយត្រូវបានរៀបចំ និងចងក្រងជាឯកសារ | អ.ន.ក |
| | | | ៣.២-សិក្ខាសាលាពិគ្រោះយោបល់ស្តីពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្ម | ១៥០ | | -របាយការណ៍វាយតម្លៃមួយត្រូវបានរៀបចំ និងចងក្រងជាឯកសារ<br>-គោលការណ៍តាមដាន និងវាយតម្លៃគុណភាពសេវាផ្សព្វផ្សាយកសិកម្មត្រូវបានរៀបចំឡើង | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| វិធានការ រយៈពេល មធ្យម និង វែង | ការបង្កើនផលិតភាព និង ប្រពលវប្បកម្មដំណាំ | ៤-រៀបចំផែនការគ្រប់គ្រង់ទឹករយៈពេល១០-២០ឆ្នាំ និងដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែង<br>-កំណត់យកការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹកជាអាទិភាពសំខាន់ របស់រាជរដ្ឋាភិបាល | ៤.១-ធ្វើការអង្កេតសេដ្ឋកិច្ចគ្រួសារ មុន និង ក្រោយធ្វើវិនិយោគប្រព័ន្ធធារាសាស្ត្រ ដើម្បីប្រៀបធៀបការរីកចម្រើនរបស់កសិករក្នុងតំបន់កសាងប្រពន្ធ័ធារាសាស្ត្រ | | ៣០០ | -ទិន្នន័យនិងត្រូវបានកសាង ក្នុងតំបន់ប្រពន្ធ័ធារាសាស្ត្រ | ន.ផ.ស |
| | | | ៤.២-កំណត់រកប្រព័ន្ធដំណាំដោយយកដំណាំស្រូវជាមូលដ្ឋាន តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ | | ៣៥០ | ប្រព័ន្ធដំណាំដោយយកដំណាំស្រូវ ជាមូលដ្ឋាន ចំនួន ៤៥ កន្លែង នឹងត្រូវបានចូលរួមវាយតម្លៃដោយកសិករចំនួន ១.០០០ នាក់ | កាឌី |
| | | | ៤.៣-បញ្ជ្រាបការបញ្ចូលស្រូវពូជទាំង ១០ តាមរយៈការដឹកនាំកសិករផលិត និងសម្រិតសម្រាំងគ្រាប់ពូជស្រូវតាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ | | ២៥០ | ប្រព័ន្ធផលិតកម្មពូជស្រូវចំនួន ១៥ នឹងត្រូវបានដំណើរការ | កាឌី |
| | | | ៤.៤- បង្ហាញនូវបង្គុំបច្ចេកវិទ្យាបង្កើននូវផលិតភាពដំណាំស្រូវ តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនៅក្នុងប្រព័ន្ធស្រោចស្រពចំនួន ១៥ ក្នុងរយៈពេល ៣ ឆ្នាំ | | ៦០០ | កសិករគំរូចំនួន ៧៥ នាក់បានចេះធ្វើ និងកសិករចំនួន ២.២០០ នាក់ទៀតត្រូវបានយល់ដឹង | កាឌី |
| | | ៥-បង្កើនការវិនិយោគលើការស្តារឡើងវិញនូវស្ថានីយ៍ មណ្ឌលអភិវឌ្ឍន៍ និងកសិដ្ឋាន ដើម្បីបម្រើការងារស្រាវជ្រាវអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាគាំទ្រដល់ផលិតកម្មកសិកម្ម | ៥.១- ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តស្ថានីយ៍កសិដ្ឋាននិងមណ្ឌលអភិវឌ្ឍន៍កសិកម្ម | | ៨.០០០ | ហេដ្ឋារចនាសម្ពន្ធ័រូបវន្តស្ថានីយ៍ ចំនួន ៧ ត្រូវបានជួសជុល ឱ្យដំណើរការល្អឡើងវិញ | អ.ន.ក |
| | | | ៥.២-បំពាក់ឧបករណ៍ និងបរិក្ខារចាំបាច់ សម្រាប់គាំទ្រការស្រាវជ្រាវនិងផ្ទេរបច្ចេកវិជ្ជាផលិតកម្មដំណាំស្រូវនៅតាមស្ថានីយ៍ កសិដ្ឋាន និងមណ្ឌល អភិវឌ្ឍន៍កសិកម្ម | | ៦.០០០ | ស្ថានីយ៍ កសិដ្ឋាននិងមណ្ឌលអភិវឌ្ឍន៍ចំនួន ០៧ ត្រូវបានបំពាក់ឧបករណ៍ និងបរិក្ខារចាំបាច់ | អ.ន.ក |
| | | | ៥.៣-ជួសជុលនិងសាងសង់មជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលមន្ត្រីជំនាញ អ្នកផ្សព្វផ្សាយ និងកសិករនៅស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម | | ៦.០០០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលចំនួន៧កន្លែងក្នុងស្ថានីយទាំង៧ ត្រូវបានសាងសង់ | អ.ន.ក |
| | | | ៥.៤-បន្តផលិតគ្រាប់ពូជសុទ្ធអនុញ្ញាត នៅស្ថានីយ៍កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម | | ៨.០៦៤ | គ្រាប់ពូជសុទ្ធអនុញ្ញាត ៤.៨០០ តោន លើផ្ទៃដី១.៦០០ហ.ត ត្រូវបានផលិត និងផ្គត់ផ្គង់ជូនសហគមន៍កសិករ ដើម្បីផលិតគ្រាប់ពូជសុទ្ធល្អ | អ.ន.ក |
| | | | ៥.៥-ធ្វើពិសោធន៍ស្រាវជ្រាវ ច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ នៅស្ថានីយ៍ កសិដ្ឋាន និង មណ្ឌលអភិវឌ្ឍន៍កសិកម្ម | | ២.០០០ | ពិសោធន៍ចំនួន ៨០០ ត្រូវអនុវត្តក្នុងរយៈពេល ៤ឆ្នាំ | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.៦-ពង្រីកការបណ្តុះបណ្តាលកសិករ អំពីបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ | | ៥.០០០ | កសិករ ៦០.០០០នាក់ ត្រូវបានបណ្តុះបណ្តាល ២០០វគ្គ ក្នុង ១០ ខេត្ត រយៈពេល ៤ ឆ្នាំ | អ.ន.ក |
| | | | ៥.៧-ពង្រីកការបណ្តុះបណ្តាល កសិករអំពីផលិតកម្មពូជសុទ្ធល្អ នៅតាមសហគមន៍កសិកម្ម | | ៣០០ | កសិករ ២.៤០០ នាក់ នៅ ៨០ សហគមន៍ ត្រូវបានបណ្តុះបណ្តាល | អ.ន.ក |
| | | | ៥.៨-ចុះពិនិត្យនិងផ្តល់ជំនួយបច្ចេកទេស ក្នុងការផលិតពូជសុទ្ធល្អ នៅតាមសហគមន៍ និងក្រុមហ៊ុន ដើម្បីចែកចាយធ្វើផលិតកម្ម | | ២៥០ | សហគមន៍ចំនួន ១០០ និងក្រុមហ៊ុន ៥ ត្រូវបានពិនិត្យ និងផ្តល់បច្ចេកទេស | អនក |
| | | | ៥.៩-ចុះសិក្សា និង វាយតម្លៃបន្ថែម អំពីពូជស្រូវដែលឆ្លើយតបនឹងទីផ្សារ | | ១៥០ | ប្រភេទពូជដែលឆ្លើយតបនឹងទីផ្សារ ត្រូវបានវាយតម្លៃ និងកំណត់បន្ថែមនៅ ១០ ខេត្ត | អនក |
| | | | ៥.១០-ពង្រីកការធ្វើស្រែបង្ហាញអំពីបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវតាមសហគមន៍ | | ៧.៥០០ | ស្រែបង្ហាញចំនួន ៣.០០០ កន្លែង ត្រូវបានអនុវត្ត (៤ឆ្នាំ) | អនក |
| | | | ៥.១១-រៀបចំសិក្ខាសាលាផ្សព្វផ្សាយបច្ចេកទេសប្រចាំឆ្នាំ ដើម្បីចែករំលែកបទពិសោធន៍ល្អៗ ក្នុងប្រពលវប្បកម្មដំណាំស្រូវ | | ៣០០ | សិក្ខាសាលាផ្សព្វផ្សាយបង្កំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវត្រូវបានរៀបចំ ១ឆ្នាំម្តង (៤ឆ្នាំ) | អនក |
| | | | ៥.១២-រៀបចំទស្សនកិច្ចសិក្សាក្នុងប្រទេស ដល់កសិករ ដើម្បីផ្លាស់ប្តូរបទពិសោន៍ល្អៗ | | ៩០០ | ទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ១០០ ត្រូវបានរៀបចំរយៈពេល ៤ឆ្នាំ | អនក |
| | | | ៥.១៣-រៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេស សម្រាប់មន្ត្រីបច្ចេកទេស និងកសិករ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងទទួលបានចំណេះដឹងចំណេះធ្វើថ្មីៗ | | ៩០០ | ទស្សនកិច្ចសិក្សាក្រៅប្រទេស ចំនួន ២០ ត្រូវបានរៀបចំ រយៈពេល ៤ឆ្នាំ | អនក |
| | | | ៥.១៤-ផលិតឧបករណ៍កសិកម្ម និងគ្រឿងយន្តកសិកម្មសាកពិសោធន៍ សម្រាប់ការរៀបចំដីដាំដុះ | | ៥០០ | ឧបករណ៍ និងគ្រឿងយន្តកសិកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចត្រូវបានបង្កើតឡើង | អនក |
| | | | ៥.១៥-ការធ្វើបង្ហាញ និង ប្រសិទ្ធភាពឧបករណ៍ និងគ្រឿងយន្តកសិកម្ម ដែលបានផលិត ដើម្បីផ្តល់ក្នុងការប្រើប្រាស់ឧបករណ៍ និងគ្រឿងយន្តកសិកម្ម សំដៅបង្កើនផលិតភាពប្រពលវប្បកម្មដំណាំស្រូវ | | ២០០ | កសិករ ១.២៥០ នាក់ បានចូលរួម និងទទួលចំណេះដឹង | អនក |
| | | | ៥.១៦-បើកវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាក្រោយពេលប្រមូលផលស្រូវ | | ២.៥០០ | វគ្គបណ្តុះបណ្តាលចំនួន ៥០០ វគ្គ មានកសិករចូលរួមចំនួន ១៧.៥០០ នាក់ ត្រូវបានរៀបចំ | អនក |
| | | | ៥.១៧-បើកវគ្គបណ្តុះបណ្តាលបច្ចេកទេស ស្តីពីការថែទាំជួសជុលគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម | | ១.៦០០ | កសិករ ចំនួន៧.៥៦០នាក់បានទទួលចំណេះពីការប្រើប្រាស់ថែទាំជួសជុលគ្រឿងយន្ត និងឧបករណ៍កសិកម្ម | អនក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ៥.១៨-បន្តត្រៀមថ្នាំកសិកម្មនិងឧបករណ៍សម្រាប់អន្តរាគមន៍បន្ទាន់កម្ចាត់សមាសភាពចង្រៃនៅពេលមានការផ្ទុះឡើងការបំផ្លាញ | | ៣.០០០ | ដំណាំស្រូវប្រមាណ ៦០.០០០ហិកតាក្នុងរយៈពេល០៥ឆ្នាំ ដែលទទួលរងការបំផ្លាញត្រូវបានការពារ | អនក |
| | | | ៥.១៩-សង់ប្រឡាយបេតុងរំដោះទឹក ស្តារប្រឡាយក្នុងបរិវេណវិទ្យាស្ថាន និងជីកប្រឡាយនាំទឹកពីប្រឡាយទឹកខាងលិចមកប្រឡាយក្នុងវិទ្យាស្ថាន (ថវិកាបន្ថែម) | | ២.១០០ | បញ្ហាខ្វះខាតទឹក និងជន់លិចពិសោធន៍ នឹងត្រូវបានកាត់បន្ថយជាអតិបរិមា | កាឌី |
| | | | ៥.២០-គ្រោងស្តុក និងផ្តល់ឥណទានស្រូវពូជមានគុណភាព ខ្ពស់ប្រចាំឆ្នាំ សម្រាប់ត្រៀមការស្តារការខូចខាតដោយគ្រោះធម្មជាតិទឹកជំនន់ និងគ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត | | ១៣.០០០ | ស្រូវពូជចំនួន ១.០០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារត្រូវបានផ្តល់ជូនកសិករខ្ចីប្រើប្រាស់រៀងរាល់ឆ្នាំសម្រាប់ស្តារការខូចខាត ដោយគ្រោះធម្មជាតិ | ន.ផ.ស |
| | | | ៥.២១-ស្រូវពូជត្រៀមអន្តរាគមន៍សង្គ្រោះបន្ទាន់ ប្រចាំឆ្នាំសម្រាប់ការស្តារការខូចខាតដោយគ្រោះធម្មជាតិទឹកជំនន់ និង គ្រោះរាំងស្ងួត តាមបណ្តារាជធានី-ខេត្ត | | ៦.៥០០ | ស្រូវពូជចំនួន ៥០០ តោន ដែលមានគុណភាពខ្ពស់ និងតម្រូវការទីផ្សារត្រូវបានចែកជូនកសិករប្រើប្រាស់រៀងរាល់ឆ្នាំដើម្បីស្តារការខូចខាតដោយគ្រោះធម្មជាតិ | ន.ផ.ស |
| | | | ៥.២២-សាងសង់ឃ្លាំងសម្រាប់ស្តុកស្រូវពូជ តាមស្តង់ដារបច្ចេកទេសត្រឹមត្រូវនៅតាមបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ទាំង ១៧ ដើម្បីរក្សាគុណភាពដំណុះស្រូវពូជ និងបរិមាណស្រូវពូជ | | ៤.៧៦០ | -ឃ្លាំងស្តុកស្រូវពូជតាមស្តង់ដាបច្ចេក-ទេស ចំនួន ១៧ ត្រូវបានសាងសង់ | ន.ផ.ស |
| | | ៦-ពង្រឹករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម ដល់ថ្នាក់ឃុំ | ៦.១- ការរៀបចំរចនាសម្ព័ន្ធ តួនាទីភារកិច្ចមណ្ឌលកសិកម្មឃុំសង្កាត់<br>• ចុះសិក្សា និងប្រមូលព័ត៌មាន សម្រាប់រៀបចំរចនាសម្ព័ន្ធរបស់មណ្ឌលកសិកម្មចំណុះការិយាល័យកសិកម្មក្រុង ស្រុកខ័ណ្ឌ និងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្ម ឃុំ សង្កាត់ | ២៥ | | នៅដើមឆ្នាំ២០១៣ រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្ម ឃុំ សង្កាត់ចំនួន ១.៦២១ ត្រូវបានប្រកាសដាក់ឲ្យអនុវត្ត | ន.ប.អ.ធ |
| | | | • រៀបចំសេចក្តីព្រាងតួនាទី ភារកិច្ចរបស់មណ្ឌលកសិកម្ម ឃុំ សង្កាត់ | ២ | | | ន.ប.អ.ធ |
| | | | • រៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅតំបន់គោលដៅ ចំនួន០៤ | ១០២ | | | ន.ប.អ.ធ |
| | | | • រៀបចំសិក្ខាសាលាថ្នាក់ក្រសួងដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងរចនាសម្ព័ន្ធ និងតួនាទីភារកិច្ច | ១៨ | | | ន.ប.អ.ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | របស់មណ្ឌលកសិកម្មឃុំ សង្កាត់ | | | | |
| | | | ៦.២-<u>ការពង្រាយមន្ត្រីរាជការឲ្យដល់មូលដ្ឋានមណ្ឌលកសិកម្ម ឃុំសង្កាត់</u><br>. រៀបចំសិក្ខាសាលាថ្នាក់កណ្តាល និងរាជធានីខេត្តដើម្បីពិគ្រោះយោបល់រកវិធីសាស្ត្រ និងតម្រូវការមន្ត្រីរាជការ<br>. រៀបចំសារាចរណែនាំដល់មន្ទីរកសិកម្មរាជធានី-ខេត្ត ដើម្បីជំរុញមន្ត្រីរាជការដែលមានស្រាប់ក្នុងមន្ទីរកសិកម្ម ឲ្យបំពេញការងារដល់មណ្ឌលកសិកម្ម ឃុំសង្កាត់<br>.រៀបចំផែនការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី | | ៦៦ | នៅដំណាច់ខែ កញ្ញា ឆ្នាំ ២០១៣ វិធីសាស្ត្រ ស្តីពីការពង្រាយមន្ត្រីរាជការ និងតម្រូវការមន្ត្រីរាជការថ្នាក់មូលដ្ឋាន បានរៀបចំរួចរាល់ | ន.ប.អ.ធ |
| | | | ៦.៣-<u>ការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីមូលដ្ឋាន</u><br>.រៀបចំវគ្គបណ្តុះបណ្តាលលើការងាររដ្ឋបាលគ្រប់គ្រង ការរៀបចំផែនការ ការងារគណនេយ្យ ចំនួន២៤ វគ្គ<br>.ពង្រាយមន្ត្រីរាជការដល់មណ្ឌលកសិកម្មឃុំសង្កាត់<br>.សាងសង់មណ្ឌលកសិកម្មនៅតាមឃុំសង្កាត់ | | ២១.៧១០ | នៅដំណាច់ឆ្នាំ២០១៥ មន្ត្រីរាជការថ្នាក់មូលដ្ឋានចំនួន១.៦២១ នាក់ត្រូវបានពង្រឹងសមត្ថភាព<br>-មន្ត្រីរាជការពី ៣-៥ រូប បានបញ្ជូនដល់ឃុំសង្កាត់គោលដៅនីមួយៗ<br>-មណ្ឌលកសិកម្មចំនួន ៤០០ យ៉ាងតិច ត្រូវបានសាងសង់នៅតាមឃុំសង្កាត់ | ន.ប.អ.ធ<br>អនក |
| | | | ៦.៤-បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក | ១.០០០ | | មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុកចំនួន៨០០ នាក់ ត្រូវបានបណ្តុះបណ្តាលនៅឆ្នាំ ២០១១ | អ.ន.ក |
| | | | ៦.៥-បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ-ឃុំ | ១.០០០ | | ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ-ឃុំចំនួន ១.៦០០ នាក់ ត្រូវបានបណ្តុះបណ្តាល | អ.ន.ក |
| | *បន្តលើកកម្ពស់ការចងក្រងរចនាសម្ព័ន្ធអង្គការកសិករ* | ៧-រៀបចំគម្រោងផែនការដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធអង្គការកសិករ -ពង្រឹងតួនាទីរបស់រចនាសម្ព័ន្ធអង្គការកសិករដើម្បីធ្វើការសម្របសម្រួលដោះស្រាយបញ្ហាផលិតកម្ម តម្រូវការ និងកង្វល់នានារបស់កសិករ ។ | ៧.១-ចងក្រងក្រុមកសិករឲ្យទៅជាសហគមន៍កសិកម្ម | | ៩៤៤ | សហគមន៍កសិកម្ម ១៣០ ត្រូវបានបង្កើតឡើងនៅតាមខេត្តគោលដៅ | អនក |
| | | | ៧.២-ធ្វើសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនាំស្រូវចេញរបស់រដ្ឋាភិបាល ដល់សហគមន៍កសិកម្ម | | ១៥០ | សហគមន៍កសិកម្មចំនួន ១៣០នៅក្នុងខេត្តគោលដៅទាំង១០នឹងយល់ដឹងអំពីគោលនយោបាយនាំស្រូវចេញរបស់រដ្ឋាភិបាលនិងទទួលបានការលើកទឹកចិត្ត | អនក |
| | | | ៧.៣-រៀបចំចងក្រងបណ្តាញសហគមន៍កសិកម្ម | | ៧០ | -បណ្តាញសហគមន៍កសិកម្មនឹងត្រូវបានបង្កើតឡើង | អនក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | *(Farmer Organization )* | | ៧.៤-រៀបចំសហគមន៍កសិកម្មចំនួន ១៣០ នៅខេត្តគោលដៅចំនួន១៣ | | ១.៣០០ | សហគមន៍កសិកម្មចំនួន ១៣០ ត្រូវបានបង្កើត | អ.ន.ក |
| | | | ៧.៥-សិក្ខាសាលាពីការធ្វើជំនួញស្រូវ-អង្ករ ដល់សហគមន៍កសិកម្ម | | ១៣០ | សហគមន៍កសិកម្មចំនួន ១៣០ យល់ដឹងពីការធ្វើជំនួញស្រូវ-អង្ករ | អ.ន.ក |
| | | | ៧.៦-រៀបចំចងក្រងបណ្តាញធុរកិច្ចសហគមន៍កសិកម្ម នៅថ្នាក់ជាតិ និងតាមខេត្តគោលដៅ | | ៧០ | បណ្តាញធុរកិច្ចសហគមន៍កសិកម្មថ្នាក់ជាតិមួយ និងថ្នាក់ខេត្តចំនួន១៣ត្រូវបានបង្កើតឡើង | អ.ន.ក |
| | | ៨.លើកកម្ពស់សមត្ថភាពរបស់កសិករ និង សហគមន៍កសិកម្ម ក្នុងការខ្ចី និងការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ៨.១-ពង្រឹងសមត្ថភាពសហគមន៍កសិកម្មលើ<br>.ការងារដឹកនាំ និងរដ្ឋបាល<br>.ការគ្រប់គ្រងបញ្ជីគណនេយ្យសហគមន៍<br>.ផែនការមុខជំនួញ | | ៧៦០ | -ហិរញ្ញិក និងថ្នាក់ដឹកនាំសហគមន៍ចំនួន៨០០ នាក់យល់ដឹងអំពីការគ្រប់គ្រងគណនេយ្យ<br>-ថ្នាក់ដឹកនាំសហគមន៍ ៨០០ នាក់យល់ដឹងអំពីភាពជាអ្នកដឹកនាំ និង ការងាររដ្ឋបាល<br>- ថ្នាក់ដឹកនាំ និង កសិករសហគមន៍ចំនួន១.៦០០ នាក់យល់ដឹងអំពីការផែនការមុខជំនួញ<br>-ក្រុមសន្សំប្រាក់ចំនួន៦០ របស់សហគមន៍ត្រូវបានបង្កើតឡើង | អនក |
| | | | ៨.២-ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដើម្បីគាំទ្រ ដល់ សហគមន៍កសិកម្ម | | ២.០០០ | សហគមន៍កសិកម្មចំនួន ២០ បានទទួលសេវាកម្មគាំទ្រ លើការសំងួតនិងឃ្លាំងស្តុកទុកស្រូវ | អនក |
| | | | ៨.៣-ពង្រឹងសហគមន៍កសិកម្មលើការងារគ្រប់គ្រងការគ្រប់គ្រងបញ្ជីគណនេយ្យ និងការធ្វើជំនួញ | | ៨០០ | អ្នកដឹកនាំ និងបេឡាសហគមន៍កសិកម្មចំនួន៩១០នាក់មានសមត្ថភាពគ្រប់គ្រងការងារគណនេយ្យ និងការធ្វើផែនការជំនួញ | អ.ន.ក |
| | | | ៨.៤-កសាងឡសម្ងួត និងឃ្លាំងស្តុកកសិផលដល់សហគមន៍ចំនួន ២០ | | ២.០០០ | ឡសម្ងួត និងឃ្លាំងស្តុកស្រូវចំនួន ២០ ត្រូវបានសាងសង់ | អ.ន.ក |
| | *លើកកម្ពស់ និងជំរុញការអនុវត្តគោលនយោបាយនៃការប្រើប្រាស់ដី* | ៩- រៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើ ប្រាស់ដីនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយ | ៩.១-ចាត់ថ្នាក់ និងវាយតម្លៃភាពសមស្របនៃដីសម្រាប់ដំណាំកសិកម្ម តាមរយៈ<br>-សិក្សាស្រាវជាមូលដ្ឋាន ក្នុងការប្រមូលផ្តុំ ទិន្នន័យដែលមានកន្លងមក ពាក់ពន្ធ័នឹងការវាយតម្លៃ ប្រភេទដីសម្រាប់ដំណាំកសិកម្ម ព្រមទាំងផ្ទៀងផ្ទាត់តាមរយៈចុះអង្កេតផ្ទាល់ដល់ទីវាលជាក់ស្តែង ដើម្បីរៀបចំគូរព្រំប្រទល់ដី<br>-ចុះសិក្សាអង្កេត និងវាយតម្លៃពីលក្ខណៈ របស់ដីនិង | | ២.៧០០ | ចំណាត់ថ្នាក់ដី និងផែនទីដីកម្រិតថ្នាក់ជាតិទាំង១៣ ខេត្ត ត្រូវបានរៀបចំ | អនក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កសិកម្ម ប្រកបដោយ ចីរភាព | | សក្តានុពលរបស់ដី ដើម្បីកំណត់ចំណាត់ថ្នាក់ដី និង បង្កើតផែនទីដីបឋម ឈានទៅកសាងផែនការប្រើប្រាស់ដីកសិកម្ម សម្រាប់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព នៅតំបន់គោលដៅ ១៣ ខេត្ត | | | | |
| | | | ៩.២-រៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកសិកម្ម របស់ក្រុមហ៊ុនវិនិយោគឯកជនចំនួន៩៥ ក្រុមហ៊ុន ក្នុងខេត្តចំនួន ១៧ | | ៤៥០ | ផែនទីរួមចំណាត់ថ្នាក់ដីកសិកម្មរបស់ក្រុមហ៊ុនវិនិយោគ ចំនួន៤ផ្ទាំង និងផែនទីចំណាត់ថ្នាក់ដីកសិកម្មរបស់ក្រុមហ៊ុនវិនិយោគឯកជនចំនួន ៩៥ ផ្ទាំង ត្រូវបានផលិត | ន.ផ.ស |
| | | | ៩.៣-កំណត់តំបន់ប្រើប្រាស់ដីកសិកម្ម នៅខេត្តកំពង់ធំ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងឧត្តរមានជ័យ | | ១.៤០០ | ផែនទីប្រើប្រាស់ដីសំរាប់ដំណាំកសិកម្មកម្រិតជាតិ ទាំង១៣ ខេត្ត នឹងត្រូវបានផលិត | អនក |
| | | ១០- រៀបចំកសាងច្បាប់ស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម សំដៅធ្វើឲ្យការប្រើប្រាស់ដីកសិកម្ម ប្រកបដោយ ចីរភាពនិងប្រសិទ្ធភាពខ្ពស់ | ១០.១-រៀបចំកសាងច្បាប់ ស្តីពី «ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម» | | ៤៧០ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ត្រូវបានរៀបចំត្រឹមឆ្នាំ ២០១៣ | អនក |
| | | | ១០.២- ពង្រឹងសមត្ថភាពនិងបញ្ជ្រាបការប្រើប្រាស់ដីនិងសម្ភារកសិកម្មសម្រាប់ដំណាំស្រូវ | | ៥.៦០០ | សមត្ថភាពវិភាគដី ជី និងថ្នាំកសិកម្មមានភាពល្អប្រសើរ | អនក |
| | | ១១ -ធ្វើជំរឿនកសិកម្មជាតិ ក្នុងរយៈពេល ១០ ឆ្នាំម្តង ដោយផ្អែកលើលទ្ធផលជំរឿនកសិកម្មជាតិនេះ ត្រូវរៀបចំផែនទីដាំដុះ | ១១.១ -រៀបចំធ្វើជំរឿនកសិកម្មជាតិ ដោយរួមសហការជាមួយក្រសួងផែនការ អង្គការ FAO និងដៃគូអភិវឌ្ឍន៍ដទៃទៀត (តម្រូវការថវិកាសរុបមានចំនួន ៤.00៨.000 ដុល្លារអាមេរិក ដែលក្នុងនោះ ថវិការាជរដ្ឋាភិបាលចំនួន ៦៩៥.000 ដុល្លារ អង្គការ FAO ចំនួន ៤៣៨.000 ដុល្លារ និង ថវិកាដែលត្រូវស្វែងរកបន្ថែម ចំនួន ២.៨៧៥.000 ដុល្លារ ពីបណ្តាដៃគូអភិវឌ្ឍន៍ផ្សេងទៀត)។ | | ១៦.០៣២ | -ទិន្នន័យនិងលទ្ធផលជំរឿនកសិកម្មជាតិ ត្រូវបានផលិត | ន.ផ.ស |
| | | | ១១.២ រៀបចំកសាងផែនទីដាំដុះដំណាំទូទាំងប្រទេស ដោយ ត្រូវធ្វើសម្ភាសន៍ ប្រមូល កែច្នៃ និងវិភាគទិន្នន័យ ដែលប្រមូលបាន ក្នុងពេលធ្វើជំរឿនកសិកម្មជាតិ ហើយ ចងក្រងរបាយការណ៍ និងផ្សព្វផ្សាយ។ | | ២.១០០ | -ទិន្នន័យផ្ទៃដីនិងផែនទីដាំដុះដំណាំទូទាំងប្រទេស ត្រូវបានផលិត | ន.ផ.ស |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ១២.ជំរុញការរៀបចំច្បាប់ស្តីពីសហគមន៍កសិកម្ម និងអនុក្រឹត្យស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា | ១២.១- រៀបចំកសាងច្បាប់ ស្តីពី «សហគមន៍កសិកម្ម» | | ៣០០ | សេចក្តីព្រាងច្បាប់ ស្តីពី «សហគមន៍កសិកម្ម» នឹងត្រូវបានរៀបចំរួច ត្រឹមឆ្នាំ ២០១៣ | អនក |
| | | | ១២.២-រៀបចំគោលនយោបាយជាតិសំរាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម | | ១២០ | គោលនយោបាយជាតិសំរាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវបានរៀបចំរួច ត្រឹមឆ្នាំ ២០១៣ | អនក |
| | | | ១២.៣- សម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសដល់សហគមន៍ផលិតស្រូវ ក្នុងភាពជាដៃគូ ជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ | | ១.៥០០ | សហគមន៍កសិកម្មគោលដៅចំនួន ១៣០ និងដៃគូពាក់ព័ន្ធទទួលបានសេវាកម្មបច្ចេកទេសតាមតម្រូវការ និងសភាពការជាក់ស្តែង | អនក |
| | | | ១២.៤- ជំរុញការពិភាក្សា និងអនុម័តលើអនុក្រឹត្យ ស្តីពី «ផលិតកម្មកសិកម្មតាមកិច្ចសន្យា» | | | អនុក្រឹត្យ ស្តីពី «ផលិតកម្មកសិកម្មតាមកិច្ចសន្យា» នឹងត្រូវអនុម័តនៅឆ្នាំ២០១១ | កសិ.ឧ |
| | | | **សរុបទឹកប្រាក់** | ១៧.៩៥៨ | ១៤១.៦៩៦ | | |
| **ពាក់ព័ន្ធនឹង ការប្រមូលទិញ និងកែច្នៃស្រូវ** | | | | | | | |
| *វិធានការរយៈពេលមធ្យម និងវែង* | *អនុវត្តទស្សនទានទីផ្សារស្រូវបើកចំហ (Open Paddy Market)* | ១៣-កសាងនិងពង្រឹងសហគមន៍កសិកម្មឲ្យមានលទ្ធភាពអនុវត្តតាមទស្សនទាន "ទីផ្សារស្រូវបើកចំហ តាមរយៈសកម្មភាពមួយចំនួនដូចជា ផលិតកម្មតាមកិច្ចសន្យាជាមួយសមាជិកសហគមន៍កសិកម្ម សេវាថ្លឹងហាលស្រូវ បញ្ចាំស្រូវ ដើម្បីយកប្រាក់ទៅប្រើប្រាស់ជាមុន ផ្តល់ពូជស្រូវមានគុណភាពខ្ពស់ និងជីគីមីជាដើម ដល់សមាជិកសហគមន៍កសិកម្ម ដើម្បីផលិតតាមតម្រូវការទីផ្សារ។ | ១៣.១-ផ្តល់វគ្គបណ្តុះបណ្តាលអំពីទស្សនទានទីផ្សារស្រូវបើកចំហ និងលិខិតបទដ្ឋានស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា | ២០០ | ១.៦០០ | ៥០ សហគមន៍កសិកម្ម និងកសិករទូទៅ ចំនួន ៩០០នាក់ ទទួលបានការបណ្តុះបណ្តាលនៅឆ្នាំ ២០១៥ | ន.ផ.ស<br>កសិ.ឧ<br>អ.ន.ក |
| | | | ១៣.២-បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពគ្រប់គ្រងទីផ្សារស្រូវបើកចំហរ និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសហគមន៍កសិកម្ម ឬ សម្ព័ន្ធសហគមន៍គំរូចំនួន ៥ | | ៤០០ | សហគមន៍គំរូចំនួន ៥ ទទួលបានការបណ្តុះបណ្តាល និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានកសាងចាប់ពីឆ្នាំ ២០១១ | អ.ន.ក<br>ន.ផ.ស<br>កសិ.ឧ |
| | | | ១៣.៣-បង្កើត និងដំណើរការទីផ្សារស្រូវបើកចំហ ដល់សហគមន៍កសិកម្មគំរូ ៥ កន្លែង | | ២.១២៥ | ទីផ្សារស្រូវបើកចំហចំនួន៥កន្លែង នឹងមានដំណើរការនៅឆ្នាំ ២០១៥ | អ.ន.ក<br>ន.ផ.ស<br>កសិ.ឧ |
| | | | **សរុបទឹកប្រាក់** | ២០០ | ៤.១២៥ | | |
| **ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញអង្ករ** ( Logistic System ) | | | | | | | |
| *វិធាន* | *ជំរុញការ* | ១៤- រៀបចំយុទ្ធសាស្ត្រអនុវត្តជាក់ស្តែងសម្រាប់អនុវត្តដោយកំណត់ | ១៤.១- រៀបចំចងក្រងឯកសារ និងផ្សព្វផ្សាយស្តីពីនីតិវិធីនៃការនាំចេញទំនិញជាកម្មវត្ថុការត្រួតពិនិត្យភូតគាម | ៥០០ | | សិក្ខាសាលាចំនួន២ដែលមានអ្នកចូលរួមចំនួន៧០រូប ត្រូវបានរៀបចំ និង | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *ការបន្ទាន់ និងផ្តល់ ផល ភ្លាមៗ* | *សម្រួលពាណិជ្ជកម្ម កាត់បន្ថយ ចំណាយ ក្រៅផ្លូវការ និងបំបាត់ ការត្រួតជជុះ* | ច្បាស់អំពីនីតិវិធីក្នុងដំណាក់កាលនីមួយៗនៃការត្រួតពិនិត្យឯកសារនាំចេញ កម្រៃត្រូវបង់ និងពេលវេលា<br>- បែងចែកការទទួលខុសត្រូវរវាង ស្ថាប័ន ពាក់ព័ន្ធឲ្យបានច្បាស់លាស់ និងមានតម្លាភាពជាសាធារណៈ<br>-ចាត់ទុកការនាំចេញអង្ករជាអាទិភាពពិសេសដោយចាត់វិធានការកាត់បន្ថយការចំណាយក្រៅផ្លូវការ និងពេលវេលានាំចេញឲ្យបានជាអតិបរមា | អនាម័យ | | | Leaflet ចំនួន 10.000 ច្បាប់ ត្រូវបានបោះពុម្ព និង ផ្សព្វផ្សាយ | |
| | | | ១៤.២- សិក្សាពីសមាសភាពចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជា, រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ, រៀបចំចងក្រង និងផ្សព្វផ្សាយអត្ថបទបច្ចេកទេស ស្តីពីសមាសភាពចង្រៃលើអង្ករ | ១.០០០ | | បញ្ជីឈ្មោះ និងសមាសភាពចង្រៃលើអង្ករត្រូវបានរៀបចំ និងរក្សាទុក និង Poster ចំនួន ៥.០០០ ច្បាប់ ត្រូវបានបោះពុម្ពផ្សព្វផ្សាយ | អ.ន.ក |
| | | | ១៤.៣- រៀបចំតំបន់គ្មានសមាសភាពចង្រៃសំរាប់ផលិតកម្មដំណាំស្រូវដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូលដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ | ១.០០០ | | អង្ករនាំចេញត្រូវបានទទួលយកដោយប្រទេសនាំចូល | អ.ន.ក |
| | *អនុវត្តយន្តការច្រកចេញចូលតែមួយ (single stop service) ដើម្បីបំពេញបែបបទនាំចេញ* | ១៥-រៀបចំ និង អនុវត្តយន្តការច្រកចេញចូលតែមួយ សម្រាប់ការបំពេញនីតិវិធីគយព្រមទាំងការចេញវិញ្ញាបនបត្រផ្សេងៗទៀត ដូចជាវិញ្ញាបនបត្រអនាម័យ និង វិញ្ញាបនបត្រភូតគាមអនាម័យ (SPS) វិញ្ញាបនបត្រធូបទកម្ម (Fumigation) វិញ្ញាបនបត្របញ្ជាក់អំពីគុណភាព បរិមាណ និងទម្ងន់ ។ | ១៥.១- ពង្រឹងសមត្ថភាព ដោយបំពាក់សម្ភារបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធូបទកម្ម (Fumigation) លើផលិតផលស្តុក និងសម្ភារវេចខ្ចប់ពីឈើ ស្របតាមស្តង់ដាអន្តរជាតិ | ៥០០ | | ប្រសិទ្ធភាពនៃការធ្វើធូបទកម្ម ត្រូវបានទទួលស្គាល់ដោយភាគីពាក់ព័ន្ធឆ្នាំ ២០១១ | អ.ន.ក |
| | *ដោះស្រាយបញ្ហាស្តង់ដារចំណាត់ថ្នាក់ និងគុណភាពឲ្យស្របតាម* | ១៦-កំណត់ស្តង់ដារគុណភាពអង្ករកម្ពុជា ឲ្យស្របតាមស្តង់ដារអន្តរជាតិ<br><br>-ស្វែងរកសមត្ថភាពបច្ចេកទេស ដើម្បីសម្រេចបាននូវស្តង់ដារទាំងនោះ។ | ១៦.១-ជំរុញនិងសហការជាមួយវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំនិងកំណត់ «ស្តង់ដារអង្ករកម្ពុជា» | | | - ស្តង់ដារអង្ករកម្ពុជានឹងត្រូវបានរៀបចំរួចនៅដើមឆ្នាំ ២០១២ | អ.ន.ក |
| | | | ១៦.២-រៀបចំផ្សព្វផ្សាយស្តង់ដារអង្ករកម្ពុជាដល់ មន្ត្រីជំនាញកសិកម្ម សមាជិកសហគមន៍កសិកម្ម សមាគមម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនប្រមូលទិញ អ្នកនាំចេញ | | ៣៤០ | - មន្ត្រីជំនាញកសិកម្ម សមាជិកសហគមន៍កសិកម្ម សមាគមម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនប្រមូលទិញ អ្នកនាំ | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ស្តង់ដារ អន្តរជាតិ | | ដែលពាក់ពន្ធ័ ក្នុងផលិតកម្ម អាជីវកម្ម នាំចេញអង្ករ | | | ចេញអង្ករ ចំនួន ២.០០០ នាក់ នឹងទទួលបានការផ្សព្វផ្សាយ អំពីស្តង់ដារអង្ករកម្ពុជា | |
| | | | ១៦.៣-រៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «គុណភាព និង សុវត្ថិភាពកសិផល» | | ១០០ | - សេចក្តីព្រាងច្បាប់ស្តីពីគុណភាព និង សុវត្ថិភាពកសិផល ត្រូវបានរៀបចំ នៅឆ្នាំ ២០១៣ | កសិ.ឱ |
| | | | ១៦.៤-បណ្តុះបណ្តាលគ្រូបង្គោល និងពង្រឹងសមត្ថភាព មន្ត្រីជំនាញ លើការគ្រប់គ្រងគុណភាព សុវត្ថិភាព ស្រូវ អង្ករ ដោយផ្អែកលើវិធាន GMP និង HACCP ។ | ៣០០ | ១.២០០<br>(២០១២-២០១៥) | - សហគមន៍គម្រូចំនួន ១៥ ម៉ាស៊ីនកិន ស្រូវចំនួន ១៥ កន្លែង និងកសិករទូទៅ ចំនួន ៧៥០នាក់ នឹងទទួលបានការ បណ្តុះបណ្តាល | កសិ.ឱ |
| វិធាន ការ រយៈ ពេល មធ្យម និង វែង | កសាង ក្របខណ្ឌ យុទ្ធសាស្ត្រ និង គតិយុត្ត ដោយផ្តោត ការយកចិត្ត ទុកដាក់ ពិសេសលើ ការគ្រប់គ្រង ប្រព័ន្ធអនា- ម័យ និង ភូតគាម អនាម័យ | ១៧-រៀបចំច្បាប់ស្តីពីភូតគាមអនាម័យ និងអនុក្រឹត្យ និងប្រកាសនានា ដែល ពាក់ព័ន្ធ<br>-ជំរុញការការអនុវត្តច្បាប់និងលិខិត បទដ្ឋានគតិយុត្ត ឲ្យមានប្រសិទ្ធភាព<br>-កំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រ អនាម័យ និងភូតគាមអនាម័យរួមមួយ ព្រមទាំងបែងចែកការទទួលខុសត្រូវ រវាងស្ថាប័នពាក់ព័ន្ធឲ្យបានច្បាស់ លាស់<br>-ពង្រឹងសមត្ថភាព និង ហេដ្ឋារចនា សម្ព័ន្ធត្រួតពិនិត្យអនាម័យ និងភូត គាមអនាម័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ | ១៧.១-រៀបចំសេចក្តីព្រាង និងដាក់ឆ្លងការពិភាក្សាតាម ដំណាក់កាលនូវច្បាប់ស្តីពីការការពាររុក្ខជាតិ និង ភូតគាមអនាម័យ | | ២៥០ | ច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាម អនាម័យត្រូវបានអនុម័តនៅឆ្នាំ ២០១៣ | អ.ន.ក |
| | | | ១៧.២-រៀបចំសេចក្តី ព្រាងច្បាប់ ស្តីពី ការគ្រប់គ្រងថ្នាំ កសិកម្ម និង ជីកសិកម្ម | (២០១១)<br>៥០ | (២០១២-១៣)<br>១០០ | សេចក្តីព្រាងច្បាប់ស្តីពីថ្នាំកសិកម្ម និង ជីកសិកម្មត្រូវបានរៀបចំ និង ច្បាប់នេះ ត្រូវបានអនុម័ត និង ប្រកាសចូលជា ធរមាន | ន.ន.ក |
| | | | ១៧.៣-រៀបចំសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធី និងការ តម្រូវបមាណីយ សម្រាប់កិច្ចបញ្ជិកាថ្នាំកសិកម្ម និង សម្ភារកសិកម្ម | (២០១១)<br>៤០ | (២០១២)<br>៤០ | សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និង ការ តម្រូវបមាណីយសម្រាប់ កិច្ចបញ្ជិកាថ្នាំ កសិកម្ម និង សម្ភារកសិកម្ម ត្រូវបាន សិក្សា និង រៀបចំរួច | ន.ន.ក |
| | | | ១៧.៤- រៀបចំប្រកាសចំនួន ៤ ដែលស្ថិតក្រោម អនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ រួមមាន៖<br>-ប្រកាស ស្តីពី សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាម អនាម័យ និងកំចាត់សមាសភាពចង្រៃ<br>-ប្រកាស ស្តីពី បញ្ជីរាយមុខទំនិញជាកម្មវត្ថុនៃការត្រួត ពិនិត្យភូតគាមអនាម័យ<br>-ប្រកាស ស្តីពី ការតែងតាំងនគរបាលយុត្តិធម៌<br>-វិសោធនកម្មប្រកាស ស្តីពី ការបង្កើតឯកសណ្ឋាន សញ្ញាសំគាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ | | ៥០០ | ប្រកាសចំនួន៤ ត្រូវបានដាក់ឲ្យប្រើប្រាស់ នៅដើមឆ្នាំ ២០១២ | អ.ន.ក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ១៧.៥- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍រោគវិនិច្ឆ័យរុក្ខជាតិ និងមន្ទីរពិសោធន៍វិភាគសំណល់ថ្នាំកសិកម្មក្នុងផលិតផលកសិកម្ម ដោយបំពាក់ឧបករណ៍ និងសម្ភារបច្ចេកទេសបន្ថែមទាំងនៅថ្នាក់កណ្តាល និងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ | | ២០.០០០ | សមត្ថភាពបច្ចេកទេសនៃការត្រួតពិនិត្យត្រូវបានពង្រឹង អាចសម្រួលដល់ការនាំចេញ- នាំចូលកសិផល | អ.ន.ក |
| | | | ១៧.៦- រៀបចំអនុក្រឹត្យ និង ប្រកាសស្តិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ | | ១០០ | អនុក្រឹត្យចំនួន ១ និងប្រកាសចំនួន ១១ ត្រូវបានរៀបចំ | អនក |
| | | | ១៧.៧-រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងអត្ថបទក្រោមច្បាប់ ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ | | ២៥០ | សិក្ខាសាលាចំនួន១០ដែលមានអ្នកចូលរួម ចំនួន ៥០០ នាក់ត្រូវបានរៀបចំ | អនក |
| | | | **សរុបទឹកប្រាក់** | ៣.៣៩០ | ២២.៨៨០ | | |
| **ទិធានការស្វែងរកទីផ្សារ** | | | | | | | |
| *វិធានការបន្ទាន់ និង ផ្តល់ផលភ្លាមៗ* | *តាមដានវិភាគ និង វាយតម្លៃស្ថានភាពទីផ្សារស្រូវ-អង្ករ* | ១៨-បង្កើតស្ថាប័នព័ត៌មានទីផ្សារស្រូវ-អង្ករ សម្រាប់ប្រមូលចងក្រងព័ត៌មានស្រូវ-អង្ករ និងវិភាគស្ថានភាពទីផ្សារតំបន់និងពិភពលោក | ១៨.១-ធ្វើសិក្ខាសាលាបំពាក់បំប៉ន ដល់មន្ត្រីទីផ្សារនៅគ្រប់រាជធានីខេត្ត អំពីវិធីសាស្ត្រនៃការប្រមូលទិន្នន័យព័ត៌មានតម្លៃទីផ្សារ | ៦៤ | ២១៦ | មន្ត្រីចំនួន៤៥នាក់ត្រូវបានចូលរួមក្នុងសិក្ខាសាលាបំពាក់បំប៉នជារៀងរាល់ឆ្នាំ | ន.ផ.ស |
| | | | ១៨.២-ចុះទៅត្រួតពិនិត្យនិងតាមដានការប្រមូលទិន្នន័យព័ត៌មានតម្លៃ | ៣៥ | ១២៧ | ការចុះទៅត្រួតពិនិត្យ និងតាមដានចំនួន ២ ដងក្នុងមួយឆ្នាំត្រូវបានធ្វើឡើង | ន.ផ.ស |
| | | | ១៨.៣-ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវ-អង្ករ ក្នុងស្រុកសម្រាប់វិភាគអំពីស្ថានការទីផ្សារក្នុងប្រទេស | ៥២ | ១៨០ | របាយការណ៍តម្លៃប្រចាំខែ និងប្រចាំឆ្នាំត្រូវបានប្រមូល និងវិភាគចងក្រងជារបាយការណ៍ | ន.ផ.ស |
| | | | ១៨.៤-ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និង ចរាចរ ស្រូវ-អង្ករ ក្នុងប្រទេស និង តាមបណ្តាខេត្តជាប់ព្រំដែន និងរៀបចំធ្វើបញ្ជីអ្នកនាំចេញអង្ករ | | ១២០ | របាយការណ៍អំពីលំហូរពាណិជ្ជកម្មស្រូវ-អង្ករ ត្រូវបានប្រមូល និងវិភាគជារៀងរាល់ឆ្នាំ និង បញ្ជីអ្នកនាំចេញអង្ករត្រូវបានចងក្រង | ន.ផ.ស |
| | | | ១៨.៥-ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវ-អង្ករ ក្នុងតំបន់និងអន្តរជាតិ សម្រាប់វិភាគអំពីស្ថានការទីផ្សារតំបន់ និងអន្តរជាតិ | ១១៩ | ៤៧០ | របាយការណ៍តម្លៃប្រចាំខែ និងប្រចាំឆ្នាំត្រូវបានប្រមូល និងវិភាគចងក្រងជារបាយការណ៍ | ន.ផ.ស |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផ្ដល់ព័ត៌មានទីផ្សារស្រូវ-អង្ករសម្រាប់តួអង្គផ្សេងៗនៃទីផ្សារក្នុងស្រុក | ១៩-បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារ និងប្រែក្លាយព័ត៌មានទាំងនោះឲ្យជាសកម្មភាពជាក់ស្ដែងទាំងក្នុងផលិតកម្មការកែច្នៃ ការនាំចេញ និងពាណិជ្ជកម្ម | ១៩.១-ផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុកក្នុងតំបន់ និងទីផ្សារអន្តរជាតិតាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រ | ៥២ | ១៧៨ | -ព័ត៌មានតម្លៃស្រូវ-អង្ករ ត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ប្រចាំថ្ងៃ សារជាអក្សរ និង គេហទំព័រ<br>-ព្រឹត្តិបត្រប្រចាំខែ និងឆ្នាំត្រូវផ្សព្វផ្សាយ | ន.ផ.ស |
| វិធានការរយៈពេលមធ្យម និងវែង | បង្កើនការប្រកួតប្រជែងក្នុងទីផ្សារតំបន់ និងពិភពលោក | ២០-កំណត់គោលដៅយុទ្ធសាស្ត្រឱ្យបានច្បាស់លាស់ដើម្បីឈរជើងលើទីផ្សារអន្តរជាតិ<br>-បន្តធ្វើសកម្មភាពស្វែងរកទីផ្សារនិងចរចាកិច្ចព្រមព្រៀងលក់<br>-ផ្សព្វផ្សាយព័ត៌មានទីផ្សារជូនដល់ផលិតករ និងអ្នកនាំចេញ<br>-កសាងសមត្ថភាពមន្ត្រីក្នុងការស្វែងរកទីផ្សារ<br>-ជំរុញការបង្កើតសមាគមប្រទេសនាំចេញអង្ករ | ២០.១-ភ្ជាប់គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ជាមួយនឹងគេហទំព័រ ទីផ្សារអង្ករអន្តរជាតិ | ៥២ | ១៨៨ | ម៉ាឃីទីងអង្ករនឹងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ | ន.ផ.ស |
| | | | សរុបទឹកប្រាក់ | ៣៧៤ | ១.៤៧៩ | | |
| | | | <u>សរុបទឹកប្រាក់រួម</u> (លានរៀល) | <u>២១.៩២២</u> | <u>១៧០.១៨០</u> | | |

**សរុបទឹកប្រាក់រួម៖** ១៩២.១០២ លានរៀល (៤៨.០២៥.០០០ ដុល្លារអាមេរិក)

**<u>សំគាល់:</u>** អ.ន.ក: អគ្គនាយកដ្ឋានកសិកម្ម

កាឌី: វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

ន.ផ.ស: នាយកដ្ឋាន ផែនការ និងស្ថិតិ

ន.ន.ក: នាយកដ្ឋាន នីតិកម្មកសិកម្ម

កសិ.ឧ: នាយកដ្ឋាន កសិ-ឧស្សាហកម្ម

ន.ប.អ.ធ: នាយកដ្ឋាន បុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស